# ជីវប្រវត្តិ

## ព្រះធម្មវិបស្សនា សំ ប៊ុនធឿន កេតុធម្មោ

ព.ស. ២៤៩៩ - ព.ស. ២៥៤៧

គ.ស ១៩៥៧ - គ.ស ២០០៣

បោះពុម្ពលើកទី២ ចំនួន ៥.០០០ ច្បាប់

ព.ស. ២៥៤៧ គ.ស. ២០០៤

រក្សាសិទ្ធិ



ព្រះធម្មវិបស្សនា សំ ប៊ុនធឿន កេតុធម្មោ
ប្រសូត្រ ថ្ងៃទី ១៨ ខែមិនា ឆ្នាំ១៩៥៧
អនិច្ចធម្ម ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០០៣

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
០៦០៣/០៥

## អារម្ភកថា

ការរៀបរៀងសៀវភៅ ជីវប្រវត្តិសង្ខេប និង និក្ខេបបទរបស់ព្រះអង្គនេះឡើង ដោយអាស្រ័យហេតុដូចតទៅនេះ:

ទី ១ : ដើម្បីបង្ហាញពីមនសិការដ៏ខ្ពង់ខ្ពស់ របស់ព្រះធម្មវិបស្សនា ព្រះសពព្រះអង្គគ្រូ **សំ ប៊ុនធឿន** អតីតកេតុធម្មោ ដែលក្នុងមួយជីវិតរបស់ព្រះអង្គបានបូជា ព្រះកាយ ព្រះបញ្ញាញាណដើម្បីបុព្វហេតុជាតិ សាសនា វប្បធម៌ឥតមានស្តាយស្រណោះឡើយ ។

ទី ២ : ដើម្បីបង្ហាញពីវីរៈភាពរបស់ព្រះអង្គ ធ្វើជាគំរូសំរាប់ខេមរជនពុទ្ធបរិស័ទ និងបព្វជិតសមណៈ អោយមានមនសិការស្រឡាញ់ជាតិ សាសនា និងវប្បធម៌របស់ខ្លួន ។

ទី ៣ : ដោយនិក្ខេបបទរបស់ព្រះអង្គមិនអាចបោះពុម្ពទាន់ពេលវេលា ក្នុងពេលដែលព្រះអង្គនៅមានព្រះជន្មនោះ ហេតុនេះ ដើម្បីរក្សានូវស្នាព្រះហស្ថរបស់ព្រះអង្គផង និងដើម្បីជាប្រយោជន៍ដល់សង្គមផងនោះ ទើបគណៈកម្មាធិការពុទ្ធមណ្ឌល បានខិតខំប្រមូលចងក្រងនិងរៀបរៀងឡើង ។ ដូច្នេះយើងខ្ញុំទាំងអស់គ្នាជឿជាក់ថានិក្ខេបបទនេះនឹងមានប្រយោជន៍ និងបានជាពន្លឺខ្លះៗ សំរាប់អ្នកដែលចង់ស្វែងយល់ពីព្រះពុទ្ធសាសនាអោយបានស៊ីជម្រៅជាក់ជាមិនខាន ។

ដោយអំណាចនៃការព្យាយាមនេះ យើងខ្ញុំទាំងអស់គ្នា សូមពូតផ្តុំឱ្យកើតទៅជាមហាកុសល ហើយសូមឧទ្ទិសមហាកុសលទាំងនោះ ប្រគេនព្រះវិញ្ញាណក្ខន្ធ

ព្រះធម្មវិបស្សនា ព្រះសពព្រះអង្គគ្រូ **សំ ប៊ុនធឿន** កេតុធម្មោ អធិបតីពុទ្ធមណ្ឌល និងជាអគ្គនាយកវិបស្សនាធុរៈសិក្សា នៃព្រះរាជាណាចក្រកម្ពុជាបានសោយនូវសុគតិភពកុំបីអាក់ខានឡើយ ។

សូមឱ្យសុខសន្តិភាព ព្រហ្មវិហារធម៌ ការមិនព្យាបាទគ្នា និងវឌ្ឍនភាពគ្រប់វិស័យទាំងអស់ប្រតិស្ឋានក្នុងដួងចិត្តខ្មែរ និងវប្បធម៌ខ្មែរជាយូរអង្វែងតទៅ !

ពុទ្ធមណ្ឌលវិបស្សនាធុរៈនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃ ៦ កើត ខែមាឃ ឆ្នាំមមែ បញ្ចស័ក ព.ស ២៥៤៧

ត្រូវនឹងថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០០៤

គណៈកម្មាធិការពុទ្ធមណ្ឌលវិបស្សនាធុរៈ

## មាតិកា


| មាតិកា | ទំព័រ |
|---|---|
| អំពីកុមារភាព | ២ |
| អំពីជីវិតផ្នួស និងប្រវត្តិនៃការសិក្សា | ៤ |
| សមិទ្ធិផលនានាដែលព្រះអង្គដឹកនាំកសាង | ១៤ |
| ការងារបណ្តុះបណ្តាល និងអប់រំ | ១៧ |
| សមណៈស័ក្តិ ដែលព្រះអង្គទទួលបាន | ២០ |
| ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ | ២៦ |
| មូលហេតុដែលនាំឱ្យព្រះពុទ្ធសាសនាបានទៅជាសាសនារបស់រដ្ឋ | ២៧ |
| ទស្សនកម្មផល | ៣៥ |
| ធុរៈក្នុងព្រះពុទ្ធសាសនា | ៤០ |
| សកម្មភាពព្រះពុទ្ធសាសនាខ្មែរនាបច្ចុប្បន្ន | ៤០ |
| គុណធម៌ដែលកើតឡើងក្នុងវិបស្សនាធុរៈ | ៤៣ |
| វិបស្សនានិងស្ត្រីខ្មែរ | ៤៥ |
| វិបស្សនានិងសង្គមខ្មែរ | ៤៦ |
| មនុស្សស្លាប់កើតទៀតឬទេ ? | ៥១ |
| ហេតុដែលនាំឱ្យមនុស្សកើតទៀត | ៦០ |

រឿងនាយចុន្ទសូករិកៈ..................................................៦៣

រឿងក្រុមញាតិស្តេចពិម្ពិសារ ....................................៦៤

រឿងបុរសពីរនាក់ជាបងប្អូនបង្កើត ...............................៦៥

រឿងក្មេងចាំជាតិ..........................................................៦៧

និព្វានធាតុ.....................................................................៧១

# ជីវប្រវត្តិសង្ខេប

## របស់ព្រះធម្មវិបស្សនា សំ ប៊ុនធឿន កេតុធម្មោ អធិបតីពុទ្ធមណ្ឌល និង ជាអគ្គនាយកវិបស្សនាធុរៈសិក្សា នៃព្រះរាជាណាចក្រកម្ពុជា

ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** ប្រសូត្រនៅថ្ងៃច័ន្ទ ៣រោច ខែ ផល្គុណ ឆ្នាំវក អដ្ឋស័ក ព.ស ២៤៩៩ ត្រូវនឹងថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៥៧ វេលាម៉ោង ១២យប់ នៅភូមិរកាកោង ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាល ក្នុងត្រកូលកសិករ ។ ញោមប្រុសនាម **ពុយ សំ** បានធ្វើមរណៈកាល ពីឆ្នាំ ១៩៩៣ ។ ញោមប្រុសជាសីលវន្ត សមាទានអតិរេកសីល (សីល ១០) រហូតដល់អស់អាយុជីវិត ។ ញោមស្រីនាម **កែវ ស៊ុម** អាយុ ៧៩ឆ្នាំ ជាសីលវតីរក្សាសីល ១០ បច្ចុប្បន្នបដិបត្តិធម៌វិបស្សនាធុរៈនៅវត្ត **រកាកោង** ស្រុកមុខកំពូល ខេត្តកណ្ដាល ។ ព្រះអង្គមានបងប្អូនបង្កើត ៤ នាក់ :

ទី១ ឧបាសិកា **សំ គង់**

ទី២ លោក **សំ ឈឿន** (ស្លាប់)

ទី៣ ព្រះតេជគុណ **សំ ប៊ុនធឿន**

ទី៤ អ្នកស្រី **សំ ចេក**

**អំពីកុមារភាព :**

កាលពីកុមារ ដោយមានលក្ខណៈសម្បត្តិមកពីធម្មជាតិ គួបផ្សំនិង ការអប់រំពីសំណាក់មាតាបិតាផងនោះ កុមារ **សំ ប៊ុនធឿន** គឺជាកុមារមួយរូប ដែលមានអត្តចរិក និងអាកប្បកិរិយាថ្លៃថ្នូរ ទន់ភ្លន់ សុភាពរាបសារ និងចេះជួយទុក្ខធុរៈអ្នកដទៃ ចេះគោរពឪពុកម្តាយ ចាស់ព្រឹទ្ធាចារ្យគួរជាទីស្រលាញ់រាប់អាន ។

លុះមានវ័យល្មមសិក្សា មាតាបិតាបានបញ្ជូនឱ្យទៅសិក្សារៀនសូត្រលេខនព្វន្តអក្សរសាស្ត្រនៅ សាលាបឋមសិក្សា **វត្តតាំងគោក** ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដែលជាទឹកដីកំណើតរបស់លោកឪពុក ។ លុះអាយុ ៨ឆ្នាំ កុមារ **សំ ប៊ុនធឿន** បានមកសិក្សានៅសាលាបឋមសិក្សា **កោះកោងក្រៅ** ស្រុកមុខកំពូល ខេត្តកណ្តាល ខាងទឹកដីកំណើតរបស់អ្នកម្តាយវិញ រហូតដល់ថ្នាក់ទី៧ ។ នៅអាយុ ១០ឆ្នាំ កុមារ **សំ ប៊ុនធឿន** ឆ្លៀតឱកាសពីការសិក្សា ទូលនំអាកោ និងនំអន្សមដើរលក់ជាមួយបងស្រី ដើម្បីរកកំរៃជួយផ្គត់ផ្គង់ជីវភាពក្រុមគ្រួសារ និងជួយដោះបំណុលចាស់ទៀតផង ។ ក្រៅពីនោះ កុមារ **សំ ប៊ុនធឿន** រែកទឹកស្រោចដំណាំគ្មានពេលទំនេរឡើយ គឺថាពេលព្រឹករែក ៥០អង្រែក ពេលល្ងាច ៥០អង្រែក ព្រមទាំងចេះជួយការងារផ្ទះបាយបានហាក់ដូចជាមនុស្សពេញវ័យធម្មតាដែរ ។

នៅអាយុ ១៣ឆ្នាំ បានប្រឡងជាប់ចូលរៀននៅអនុវិទ្យាល័យ **សេរីមង្គល** ឃុំរកាកោង ២ ស្រុកមុខកំពូល ខេត្តកណ្តាល ។

លុះអាយុ ១៦ឆ្នាំ យុវជន **សំ ប៊ុនធឿន** ត្រូវឃ្លាតពីឪពុកម្តាយមករស់នៅជាមួយបងស្រីនៅទួលគោក ទីក្រុងភ្នំពេញ ហើយបានបន្តការសិក្សានៅវិទ្យាល័យ **ពៅ អ៊ុម** ដល់ថ្នាក់ទី៣ រហូតដល់ព្រឹត្តិការណ៍ ១៧ មេសា ឆ្នាំ ១៩៧៥ ។

អាយុ ១៩ឆ្នាំ នៅក្នុងរបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃ នៃបនប្រល័យពូជសាសន៍ យុវជន **សំ ប៊ុនធឿន** ត្រូវបានជន្លៀសចេញពីទីក្រុងភ្នំពេញ ដូចប្រជាជនទូទៅដែរ ។ នៅក្នុងរបបនោះ យុវជន **សំ ប៊ុនធឿន** ត្រូវបានគេយកទៅដាក់ឃុំឃាំងអោយជាប់គុក ហើយបំរុងនឹងយកទៅសម្លាប់ ប៉ុន្តែត្រូវបានគេជួយយកអាសា និងដោយមានកុសលផលបុណ្យផងនោះ ក៏ត្រូវបានគេចផុតពីសេចក្តីស្លាប់ជាលើកទីមួយ ។ ក្រោយមកទៀត យុវជន **សំ ប៊ុនធឿន** ត្រូវបានគេចាត់អោយនៅក្នុងក្រុមចល័ត ហើយមានជម្ងឺជាទម្ងន់ រហូតពេទ្យយកទៅដាក់ចោលនៅក្នុងបន្ទប់ដាក់ខ្មោច តែអាយុមិនអស់ ក៏ដឹងស្មារតីឡើងវិញបានរួចផុតពីសេចក្តីស្លាប់ជាលើកទីពីរ ។ បន្ទាប់ពីរួចផុតពីសេចក្តីស្លាប់មក យុវជន **សំ ប៊ុនធឿន** ពុំបានរស់នៅជួបជុំគ្រួសារបងប្អូនឡើយ ត្រូវបានគេជន្លៀសអោយទៅនៅកន្លែងផ្សេងៗគ្មានឈប់ឈរ រហូតដល់ឆ្នាំ ១៩៧៩ ។

នៅថ្ងៃរំដោះ ៧មករា ១៩៧៩ យុវជន **សំ ប៊ុនធឿន** បានត្រឡប់មករស់នៅស្រុកកំណើត ហើយបានជួបជុំលោកឪពុកអ្នកម្តាយបងប្អូនវិញ ។ បន្ទាប់ពីបានជួបជុំលោកឪពុកអ្នកម្តាយបងប្អូនមក ដោយការតាំងប្រាថ្នា និងមាននិស្ស័យជាអ្នកស្រលាញ់ព្រះពុទ្ធសាសនាស្រាប់ផងនោះ យុវជន **សំ ប៊ុនធឿន** ក៏បានតាំងចិត្តថា នឹងចូលសាងព្រះផ្នួស បំរើព្រះពុទ្ធសាសនារហូតអស់មួយជីវិត ដោយមិនគិតកសាងជីវិតអាពាហ៍ពិពាហ៍ និងគ្រួសារឡើយ ។

**អំពីជីវិតផ្នួស និងប្រវត្តិនៃការសិក្សា:**

ដោយមានសទ្ធាជ្រះថ្លាញាណសម្បយុត្តនិងសូនេះចំពោះព្រះពុទ្ធសាសនាស្រាប់ផងនោះ ទើបនៅឆ្នាំ ១៩៨០ យុវជន **សំ ប៊ុនធឿន** មានអាយុ ២៤ឆ្នាំក៏បានចូលសាងព្រះផ្នួស បួសជាសមណេរនៅក្នុងពុទ្ធសីមាវត្ត **កំពង់មុនីជោត** ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ព្រះនាម **គាំ ពេញ**។ បន្ទាប់ពីសាងព្រះផ្នួសរួចមក ដោយមានការជួយណែនាំឧបត្ថម្ភ និងការពារពីសប្បុរសជនច្រើនរូបមានលោក **ម៉ី យ៉ាំ** និងលោកអាចារ្យ **អ៊ុម សារុន** ជាដើម.សាមណេរ **សំ ប៊ុនធឿន** បានខិតខំរៀនសូត្រស្វាធ្យាយធម៌អាថិមិនដែលធ្វេសប្រហែសម្តងណាឡើយ ។ រយៈកាលតែ ៧០ថ្ងៃប៉ុណ្ណោះ ព្រះអង្គបានរៀនធម៌សូត្រមន្ត និងដារបង្សុកូលបានចប់សព្វគ្រប់ ថែមទាំងទន្ទេញព្រះបាតិមោក្ខបាលី និងសេចក្តីសំរាយចាំរត់មាត់ចប់បរិបូណ៌ អាចសំដែងបានដោយមាត់ទទេយ៉ាងស្ទាត់ជំនាញ ឥតមានទាស់ខុសឡើយ ។

ឆ្នាំ១៩៨១ ព្រះជន្ម ២៥ព្រះវស្សា បានបំពេញឧបសម្បទា ជាភិក្ខុភាវៈ នៅពុទ្ធសីមាវត្ត **ឃោសិតារាម** ឃុំស្ដៅ ស្រុកកងមាស ខេត្តកំពង់ចាម ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ព្រះនាម **គង់ ណែម** និងព្រះឧបសម្បទាចារ្យ ព្រះនាម **ជួន សំអិន** ហើយ ព្រះឧបជ្ឈាយ៍អោយបព្វជិតនាមថា **កេតុធម្មោ**។ បន្ទាប់ពីបំពេញឧបសម្បទាមក ព្រះភិក្ខុ **សំ ប៊ុនធឿន** បានបំពេញការព្យាយាមក្នុងការសិក្សាកាន់តែទ្វេថែមទៀត មិនដែលតំអក់ទំរន់ម្ដងណាឡើយ ដោយស្របទៅតាមពាក្យចាស់ថា "**បួសរៀន**"។ ហេតុនេះហើយ ទើបព្រះអង្គបានមកគង់នៅវត្ត **ភ្នីចាស់** (សុរិយាពោធិមាស) ស្រុកមុខកំពូល ខេត្តកណ្ដាល ដើម្បីសិក្សាធម្មវិន័យក្នុងសំណាក់លោកអាចារ្យ **មាស ឈិន** រហូតចប់ថ្នាក់ត្រីនិងទោ ហើយអាចសំដែងធម្មទេសនាបានពីរោះក្បោះក្បាយ ជាហេតុធ្វើអោយពុទ្ធបរិស័ទមានការចូលចិត្តគោរពរាប់អានច្រើន ។

លុះឆ្នាំ ១៩៨៣ ដល់ ១៩៨៥ ព្រះអង្គបានមកគង់នៅវត្ត **ពាមមន្គល** ឃុំកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាលវិញ ។ វស្សានោះ ព្រះអង្គបានអញ្ជើញលោកគ្រូធម្មាចារ្យ **មាស ឈិន** ដដែល មកបង្រៀនបញ្ចប់ធម្មវិន័យថ្នាក់ឯកជាបន្តទៀត ។ ដោយវិរិយភាព និងព្រះទ័យជ្រះថ្លាចំពោះការសិក្សា ព្រះអង្គបានបញ្ចប់ធម្មវិន័យថ្នាក់ឯកដោយបរិបូរ ព្រមទាំងចេះចាំព្រះអភិធម្មទាំង ៧គម្ពីរ

ទាំងអត្ថទាំងព្យញ្ជនៈ ហើយមានសមត្ថភាព និងទេពកោសល្យកាន់តែចាស់ក្លា ថែមទៀត ក្នុងការសំដែងធម្មទេសនាគ្រប់ទិសទី ។

ក្នុងរយៈពេលសិក្សានោះ មានការខ្វះខាតនូវសិក្ខូបករណ៍ជាច្រើន សូម្បី តែគម្ពីរដីកាសំរាប់ស្រាវជ្រាវក៏គ្មានគ្រប់គ្រាន់ផង ។ ពេលនោះបងស្រីរបស់លោក ឈ្មោះ **សំ គន់** មានភារៈជួយដោះស្រាយគម្ពីរផ្សេងៗប្រគេនព្រះអង្គ ។ ជំនាន់ នោះមធ្យោបាយធ្វើដំណើរលំបាកណាស់ បងស្រី **សំ គន់** ធ្វើដំណើរដោយផ្ញើរ ជើងស្ថិតក្នុងសំល្បេកបំពាក់ខោក្នុងម៉ូរ៉ាជើងទទេ ដើរពីរកាកោងទៅភ្នំពេញ ដើម្បី ស្រាវជ្រាវរកគម្ពីរនៅកន្លែងនេះបន្តិច កន្លែងនោះបន្តិច បានចំនួន ៥៧គម្ពីរ ( ព្រះ ត្រៃបិដក ) ប៉ុន្តែមិនបានតាមលំដាប់លំដោយនៃលេខរៀងទេ ។ ក្រោយមកទៀត អាស្រ័យដោយបានការឧបត្ថម្ភពីលោកស្រី **ឌល្លា** ( បច្ចុប្បន្នធ្វើការនៅក្រសួង ធម្មការ និងសាសនា ) បានខ្នះខ្នែងជួយខ្ចីគម្ពីរដែលខ្វះទាំងប៉ុន្មានពីក្រសួងបាន ១ក្បាលក្នុង ១ខែ ។ ដូច្នេះសន្ទុះនៃការសិក្សារបស់ព្រះអង្គមានល្បឿនឆាប់រហ័ស បំផុត គឺព្រះអង្គព្យាយាមសិក្សារហូតដល់ចប់ ១១០ក្បាល ។ តាំងពីបព្វជ្ជាជា សមណេររហូតមក ដោយការព្យាយាមសិក្សាព្រះធម៌ខ្លាំងផង គួបផ្សំនិងការខ្វះ ខាតអាហារមិនសូវគ្រប់គ្រាន់ផងនោះ រាងកាយរបស់ព្រះអង្គមិនសូវជាមានសាច់ ឈាមប៉ុន្មានទេ គឺថា តាំងពីបួសមក ព្រះអង្គមិនដែលបានឆាន់ទូវចង្កាន់ត្រីសាច់ ឡើយ ឆាន់តែស្ងៀង នៃប៉ូវសម្បួសអស់ ៦ព្រះវស្សាគត់ ។

លុះវស្សាទី៧ ព្រះអង្គបានជួបផ្ទាល់ជាមួយ ធម្មាចារ្យនាម **រស់ ឈុន** ជាឧបាសកម្នាក់នៅបង្រៀនធម៌វិបស្សនាក្នុងវត្តពាមមង្គល អាចចេះចាំផ្នែកវិបស្សនាធុរៈបានល្អប្រពៃ ពុទ្ធបរិស័ទវត្ត **ពាមមង្គល** គោរពបូជាជាគ្រូដ៏ប្រពៃក្នុងជំនាន់នោះ ព្រមទាំងជាកល្យាណមិត្តរបស់លោកគ្រូឧទ្ទេសាចារ្យ **អ៊ុម សារុន** នៅរការកោងផង ។ នាសម័យនោះលោកអាចារ្យ **អ៊ុម សារុន** បានបវារណាព្រះអង្គអោយនិមន្តរៀនព្រះកម្មដ្ឋានជាមួយលោកគ្រូ **រស់ ឈុន** តែព្រះភិក្ខុ **សំ ប៊ុនធឿន** គេតុចម្មោ ហាក់ដូចជាមានព្រះទ័យស្ទាក់ស្ទើរ ។

តែដោយការព្យាយាមលួងលោមពីសំណាក់ធម្មាចារ្យ **រស់ ឈុន** បានបវារណាថា បើលោកម្ចាស់រៀនធម៌ជាមួយនិងលោកតាគ្រូ លោកម្ចាស់នឹងបានជាសះស្បើយរោគាពាធជាក់ជាមិនខាន. បើមិនជឿទេ សូមលោកម្ចាស់សាកល្បងតែ ៣ ថ្ងៃសិនក៏បាន ។ វាចាលោកតាគ្រូ **រស់ ឈុន** ក៏បានធ្វើអោយព្រះភិក្ខុ **សំ ប៊ុនធឿន** គេតុចម្មោ សម្រេចព្រះទ័យដាក់ធុរៈថា នឹងសាកល្បងសិក្សាមើលថាតើធម៌ពិតឬមិនពិត ។ ចាប់តាំងពីបានសាកល្បងមក រយៈកាលតែ១រាត្រីប៉ុណ្ណោះ ព្រះភិក្ខុ **សំ ប៊ុនធឿន** បានកើតធម៌ភ្លាម អាពាធទាំងឡាយដែលកើតមានកន្លងមក ដោយខ្វះជីវជាតិនោះ ក៏បានជាសះស្បើយជាបន្តបន្ទាប់ដែរ ព្រមទាំងមានការស្ងប់កាយស្ងប់ចិត្ត ពេលនោះព្រះអង្គក៏បន្តសិក្សាសមថ និងវិបស្សនា

កម្មដ្ឋានជាមួយលោកតាគ្រូ **សេង ឈុន** រហូតដល់ចប់កម្មដ្ឋានទាំង ៤០ ព្រម ទាំងឈានសមាបត្តិដោយបរិបូរ ។

ឆ្នាំ ១៩៨៥ ដល់ ១៩៩១ គ្រប់ ៧ឆ្នាំគត់ ដោយសមត្ថភាពរបស់ព្រះអង្គ កាន់តែចាស់ក្លា និងដោយការខ្វះខាតព្រះធម្មាចារ្យផងនោះ ទើបពុទ្ធបរិស័ទមាន ឧទ្ទេសាចារ្យ **អ៊ឹម សារុន** ជាដើម និមន្តព្រះភិក្ខុ **សំ ប៊ុនធឿន** អោយធ្វើ ជាព្រះធម្មាចារ្យ បង្រៀនព្រះកម្មដ្ឋានដល់ភិក្ខុ សាមណេរ យាយ តា បន្តពីលោកតា **សេង ឈុន** តទៅ ។

ឆ្នាំ ១៩៩៤ ដោយការណែនាំពីលោក **មី យ៉ាំ** ផង ដោយការចង់ចេះដឹង មិនចេះគ្រប់គ្រាន់ផងនោះ ទើបព្រះអង្គស្វះស្វែងរកសាលាបាលី ដើម្បីរៀនបន្ត ទៀត ។ ពេលនោះ ក៏បានទៅពិភាក្សា និងអង្វរករជាមួយលោកអាចារ្យ **អ៊ឹម សារុន** ដើម្បីអោយបើកសាលាបាលី ។ ពាក្យអង្វរករនេះធ្វើឱ្យរូបលោក អាចារ្យ មានកម្លាំងសទ្ធា ក៏សម្រេចបើកសាលាពុទ្ធិកបឋមសិក្សាមាន ៣ថ្នាក់ភ្លាម ដែលមានការជួយឧបត្ថម្ភពីពុទ្ធបរិស័ទជិតឆ្ងាយ មានលោកយាយ ឧបាសិកា **នៃ ឡាង** ជាញោមទី២ ជាដើម ។ ពេលនោះមានសិស្សចំនួន ៤៥ អង្គ ដែលមានព្រះធម្មាចារ្យ **សំ ប៊ុនធឿន** ជាប្រធាន ។ ក្នុងការរៀនសូត្រនេះ ព្រះធម្មាចារ្យ **សំ ប៊ុនធឿន** ដើរតួនាទីធ្វើជាសិស្សផង ធ្វើជាគ្រូផង គឺធ្វើជា ធម្មាចារ្យបង្រៀនព្រះវិន័យ និងគោលសាសនសុភាសិត ។ល។ និង ។ល។

វេរ៉ាល់ល្ងាច នៅតូបតូចរបស់ព្រះអង្គ មានពន្លឺភ្លើងចង្កៀងផ្ទុង១នាកណ្ដាលរាត្រី ពេលនោះហើយ ដែលព្រះអង្គកំពុងតែទន្ទេញមូលវេយ្យាករណ៍ភាសាបាលីរបស់លោកគ្រូ **ឈឹម ស៊ុម** ទាំង៧និទ្ទេស. ចាំមាត់អស់រយៈកាលត្រឹមតែ ៣ ខែប៉ុណ្ណោះ ។ ព្រះអង្គតែងតែសូត្រនូវមូលវេយ្យាករណ៍ ៧និទ្ទេសខាងលើនោះ ចាំរត់មាត់ដូចជាធម៌សូត្រធម្មតារាល់ថ្ងៃឥតមានការភ្លេចភ្លាំងឡើយ ។ បន្ទាប់មកទៀតព្រះអង្គក៏រៀនសម្ពន្ធមាលារបស់លោកគ្រូ **អ៊ុក ឌាំ** ចប់ទៀត ហើយអាចសម្ពន្ធបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍បាលីឥតមានទាស់ខុសឡើយ ។

លុះដល់ឆ្នាំទី២ ព្រះអង្គបានប្រែគម្ពីរធម្មបទចប់បាន ៤ភាគ ហើយយករឿងព្រមទាំងសាច់ធម៌មកសំដែង ជូនយាយ តារាល់ថ្ងៃឧបោសថសីលទៀតផង ។

ឆ្នាំទី៣ ( ១៩៩៤ ) បានប្រែគម្ពីរធម្មបទភាគ ៥ ដល់ភាគ៨ ចប់ដោយបរិបូរណ៍ ទាំងអត្ថនិងព្យញ្ជនៈមិនទើសទាល់ ។ មិនតែប៉ុណ្ណោះ ព្រះអង្គអាចសន្ទនាភាសាបាលីជាមួយប្រទេសដែលនិយាយភាសាបាលីបានខ្លះផង ។

ដោយខ្វះមធ្យោបាយ និងបង្រៀនគម្ពីរធំ១ប្រភេទព្រះអង្គបន្តទៀតបាន ដូចជា **មង្គលត្ថទីបនី វិសុទ្ធិមគ្គ** និង គម្ពីរផ្សេង១ទៀតនោះ ទើបឧទ្ទេសាចារ្យ **អ៊ុម សារុន** ក៏សម្រេចបវារណាព្រះធម្មាចារ្យ **សំ ប៊ុនធឿន** ឱ្យព្រះអង្គនិមន្តទៅបន្តការសិក្សាព្រះបរិយត្តិធម៌ថ្នាក់មធ្យម ជាមួយលោកគ្រូឧទ្ទេសាចារ្យនាម **ជឹម ឡូញ** ហៅ **ជន** នៅវត្ត **សុទណ្ណទតី** ឃុំព្រែកតាមាក់

ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ជាបន្តទៀតផង បង្រៀនវិបស្សនាធុរៈផង ។ បន្ទាប់ពីប្រែគម្ពីរខាងលើនេះ នៅពាក់កណ្តាលឆ្នាំ ១៩៩៥ សម្តេចព្រះសង្ឃរាជទ្រង់ព្រះនាម **ទេព វង្ស** ជាមួយនឹងលោក **ម៉ី យ៉ាំ** ជាទីប្រឹក្សារបស់ព្រះអង្គ ទ្រង់បានពិគ្រោះពិភាក្សារិះរកមធ្យោបាយយ៉ាងណា ធ្វើឱ្យព្រះពុទ្ធសាសនាដែលរស់ឡើងវិញនេះ បានជ្រួតជ្រាបដល់ពុទ្ធបរិស័ទទូទៅ ដើម្បីគោរពប្រតិបត្តិឱ្យបានទូលំទូលាយរីកចំរើនទៅអនាគតវែងឆ្ងាយ ។ ល ។ ព្រះអង្គទ្រង់មានព្រះតម្រិះចង់ឱ្យពុទ្ធបរិស័ទទាំងបព្វជិត ទាំងគ្រហស្ថ បានសិក្សា បានស្វែងយល់ និងគោរពប្រតិបត្តិគ្រប់ៗគ្នា ។ សម្តេចទ្រង់លើកឡើងអំពីធុរៈក្នុងព្រះពុទ្ធសាសនាទាំងពីរ គឺ គន្ថធុរៈ និងវិបស្សនាធុរៈថា ៖ គន្ថធុរៈយើងបានរៀបចំជាផ្លូវការឡើងវិញហើយ ក៏គួរយកចិត្តទុកដាក់រៀបចំខាងផ្នែកវិបស្សនាធុរៈជាផ្លូវការផងដែរ ដើម្បីអនុគ្រោះដល់ភិក្ខុសាមណេរ និងពុទ្ធបរិស័ទ ឧបាសក ឧបាសិកា ឱ្យបានសិក្សាផង ។ល។ ព្រះអង្គក៏សព្វព្រះរាជហឫទ័យដាក់បញ្ហានេះក្នុង អនុសំវច្ឆរមហាសន្និបាតលើកទី៥ឆ្នាំ ១៩៩៥ ដើម្បីពិភាក្សាអនុម័ត ។ អនុសំវច្ឆរមហាសន្និបាត ដែលមានមន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ មានព្រះរាជាគណៈ ឋានានុក្រម មេគណ អនុគណ និងមន្ត្រីធម្មការគ្រប់ថ្នាក់ចូលរួមផង បានសម្រេចជាឯកច្ឆ័ន្ទ បើកវិបស្សនាធុរៈសិក្សាផ្លូវការតទៅ ។

បន្ទាប់ពីអនុសំវច្ឆរៈមហាសន្និបាតចប់ហើយ សម្តេចព្រះសង្ឃរាជជាអម្ចាស់

ទ្រង់ត្រាស់ឱ្យលោក **ម៉ី យ៉ាំ** ស្រាវជ្រាវទូទាំងប្រទេស ជ្រើសរើសរកព្រះធម្មាចារ្យផ្នែកវិបស្សនាធុរៈ ដើម្បីរៀបចំជាផ្លូវការឱ្យសមស្របតាមការវិវឌ្ឍន៍រីកចំរើនរបស់ព្រះពុទ្ធសាសនាយើង ។ ក្នុងការស្រាវជ្រាវរកនេះ ក៏បានឃើញថា ក្រុមព្រះធម្មាចារ្យ **សំ ប៊ុនធឿន** បានសិក្សាវិបស្សនាធុរៈ តាមគម្ពីរវិសុទ្ធិមគ្គ ដែលមានព្រះត្រៃបិដកជាគោល តាំងពីលោកគ្រូធម្មាចារ្យ **សេំ ឈុន** ជាគ្រូរបស់លោកមក ។ អាស្រ័យហេតុនេះទើបសម្តេចព្រះសង្ឃរាជជាអម្ចាស់សព្វព្រះរាជហឫទ័យស្តេចយាងទៅកាន់វត្តសុវណ្ណវតី ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាលជាទីកន្លែងដែលព្រះអង្គ **សំ ប៊ុនធឿន** គង់នៅដោយផ្ទាល់ព្រះអង្គដើម្បីជួបពិភាក្សាការងារនេះជាមួយព្រះធម្មាចារ្យ **សំ ប៊ុនធឿន** និងព្រះឧទ្ទេសាចារ្យ **ជឹម ឡូញ** ( ហៅថន ) ផ្ទាល់ ។

ដោយពេលនោះកំពុងបើកវគ្គសិក្សា ព្រះធម្មាចារ្យ **សំ ប៊ុនធឿន** ជាប់ភារកិច្ចបង្រៀន ក៏សូមឱ្យនិមន្តព្រះឧទ្ទេសាចារ្យ **ជឹម ឡូញ** ( ហៅថន ) ទៅគង់នៅវត្តឧណ្ណាលោមមុន ដើម្បីគង់នៅជិតសម្តេចជាអម្ចាស់ ងាយស្រួលពិភាក្សាក្នុងការងារនេះផង និងសូមឱ្យព្រះអង្គបង្រៀនបាលីក្នុងសាលាពុទ្ធិកបឋមសិក្សាវត្តឧណ្ណាលោមផង ។

លុះកន្លងមកចំនួន ៣ខែ ( ដើមឆ្នាំ ១៩៩៦ ) ចប់ការបង្រៀននៅវត្តសុវណ្ណវតីហើយ ព្រះធម្មាចារ្យ **សំ ប៊ុនធឿន** ក៏ត្រូវនិមន្តទៅគង់នៅឯក្រុងភ្នំពេញដែរ ប៉ុន្តែព្រះអង្គសំណូមពរសូមគង់នៅវត្តណាមួយជាយក្រុងភ្នំពេញ ដែល

មានសភាពស្ងប់ស្ងាត់បង្គួរ ។ សម្តេចព្រះសង្ឃរាជជាអម្ចាស់ ក៏បានទ្រង់ត្រាស់ឱ្យអញ្ជើញលោក **ជា សុធីរ** ប្រធានគណៈកម្មការវត្តឧន្នាលោម (សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ) ទៅគាល់ព្រះអង្គ ដើម្បីស្នើសុំឱ្យរៀបចំវត្តនេះ ប្រគេនព្រះធម្មាចារ្យ **សំ ប៊ុនធឿន** គង់នៅ ហើយយកវត្តនេះជាទីស្នាក់ការ មជ្ឈមណ្ឌលវិបស្សនាធុរៈទូទាំងប្រទេសតែម្តងដែលមានព្រះធម្មាចារ្យ **សំ ប៊ុនធឿន** ជាអធិបតី ។

បន្ទាប់ពីបានឮសម្តេចព្រះសង្ឃរាជជាអម្ចាស់ផ្តុកផ្តាក់ការងារនេះភ្លាមលោក **ជា សុធីរ** ហាក់ដូចជាភ្ញាក់លាន់មាត់ថា ៈឱ ហ្ន៎ ! ពេលនេះសម្តេចជាអម្ចាស់ប្រទានវត្តដ៏មានតម្លៃថ្លៃលើសពេជ្របុីនដូងទុំរាប់លានដុំទៅទៀត ទូលព្រះបង្គំរំភើបណាស់ រំភើបអ្វីម្ល៉េះទេ ទូលព្រះបង្គំសូមទទួលព្រះរាជាឱង្ការតំកល់លើត្បូង ។ល។ បន្ទាប់មកលោក **ជា សុធីរ** បានប្រជុំព្រះសង្ឃ គណៈកម្មការវត្តព្រមព្រៀងគ្នាជាឯកច្ឆ័នដោយអំណរសាទរយ៉ាងក្រៃលែង ហើយក៏បានរៀបចំវត្តធ្វើកុដិប្រគេនព្រះអង្គគង់នៅយ៉ាងសមរម្យ ។

ឆ្នាំ ១៩៩៥ (រយៈពេលដែលព្រះធម្មាចារ្យ **សំ ប៊ុនធឿន** គង់នៅវត្តសុវណ្ណវតី ) មានសប្បុរសជនម្នាក់នាម **ស្រី ជាសាធារណ៍** និងលោកស្រី **ហ៊ុយ សារី** មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានវេរប្រគេនដីមួយកន្លែងស្ថិតខាងលិចភ្នំអង្គរស្ស ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ដល់ព្រះសង្ឃមានសម្តេចព្រះសង្ឃរាជ **ទេព វង្ស** និងព្រះធម្មាចារ្យ **សំ ប៊ុនធឿន** ជាប្រធាន

សូមព្រះអង្គទ្រង់ព្រះមេត្តា ទទួលទុកជាសម្បត្តិរបស់ព្រះពុទ្ធសាសនាវែងឆ្ងាយតទៅ ។ នៅពេលទទួលរួចហើយ សម្ដេចជាអម្ចាស់បានប្រសិទ្ធិនាម ជាដំបូងថា : **អាស្រមសន្តិវ័ន** ។ ក្រោយមក **អាស្រមសន្តិវ័ន** ជាសាខារបស់ មជ្ឈមណ្ឌលវិបស្សនាធុរៈវត្តឧទ្ទុមុនី ដោយបាន និមន្តព្រះភិក្ខុសង្ឃ សាមណេរ ឧបាសក ឧបាសិកាខ្លះ មានព្រះភិក្ខុ **ស្រី ជាសុម៉េត** និងធម្មាចារ្យ ឧបាសិកា **ស្រី ជាព្រហ្មចារិនី** ជាដើម ឱ្យនៅគ្រប់គ្រង និងដឹកនាំបដិបត្តិ ព្រះធម៌វិបស្សនានៅទីនោះ ។

ឆ្នាំ ២០០០ មជ្ឈមណ្ឌលវិបស្សនាធុរៈ ឧទ្ទុមុនី ក៏ត្រូវបានប្រកាសតែងតាំងជាពុទ្ធមណ្ឌលវិបស្សនាធុរៈ តាមប្រកាសតែងតាំងលេខ ៨៦/២០០០ ក.ស.រ.ក. ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០០០ ដែលមានព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** ជាអធិបតី និងជាអគ្គនាយកវិបស្សនាធុរៈសិក្សា នៃព្រះរាជាណាចក្រកម្ពុជា ។

ការរីកចម្រើនលើការផ្សព្វផ្សាយព្រះធម៌មានទំហំធំធេង ដែលសភាពការណ៍ជាក់ស្ដែងនៅវត្តឧទ្ទុមុនី មិនអាចទទួលសិស្សស្នាក់នៅបានតាមសំណូមពរ អាស្រ័យហេតុនេះ ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** ក៏បានថ្វាយយោបល់ និងទទួលព្រះរាជានុញ្ញាតិពីសម្ដេចព្រះសង្ឃរាជជាអម្ចាស់ផ្លាស់ប្ដូរទីតាំង ពីវត្តឧទ្ទុមុនី មកអាស្រមសន្តិវ័ន នៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០០០ ហើយប្ដូរនាមពីអាស្រមសន្តិវ័នមកជាពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជារហូតមក ។

បន្ទាប់ពីមកគង់នៅទីនេះ ព្រះអង្គពុំសូវមានពេលទំនេរទេ មួយថ្ងៃៗមាន ការងារជាច្រើនដែលត្រូវបំពេញ ដូចជា ការរៀបចំផ្សព្វផ្សាយព្រះធម៌ តាមរយៈ ការចងក្រងនិងនិពន្ធសៀវភៅ ការសំដែងធម៌ និងការរៀបចំគ្រប់គ្រងនៅទីនេះ ជាដើម ។ល។និង។ល។ ទោះបីជាការងារមានទំហំដ៏ធំធេងយ៉ាងណាក៏ដោយ ក៏ព្រះអង្គពុំដែលមានការត្អូញត្អែរម្តងណាឡើយ ។ មួយវិញទៀត ព្រះអង្គគឺជា ព្រះសង្ឃមួយអង្គ ដែលមានវីរិយភាពដ៏ខ្លាំងក្លាបំផុត ចំពោះវិស័យអប់រំ ជាពិសេស គឺការរៀនសូត្រផ្ទាល់ ព្រះអង្គនេះតែម្តង ។ ដូច្នេះហើយបានជានៅថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ២០០០ ព្រះអង្គបានបន្តការសិក្សានៅពុទ្ធិកសាកលវិទ្យាល័យព្រះ សីហនុរាជជាបន្តទៀត ។ ក្នុងការសិក្សានៅពុទ្ធិកសាកលវិទ្យាល័យនេះ មានមុខ វិជ្ជាជាច្រើនដែលត្រូវរៀនសូត្រដូចជា សង្គមវិទ្យា **( Sociology)** , ច្បាប់ **(Law)** , នរវិទ្យា **( Anthropology)** , វិទ្យាសាស្រ្តអប់រំ **(Educational Science)**, តក្កវិទ្យា **( Logic and Critical Thinking )** និង ទស្សនៈវិទ្យា **( Phylosophy)** ជាដើម តែមុខវិជ្ជាដែលព្រះអង្គពេញចិត្តនោះគឺ ទស្សនវិទ្យា ព្រះពុទ្ធសាសនា **( Buddhish Philosophy )** ។

## សមិទ្ធិផលនានាដែលព្រះអង្គដឹកនាំកសាង

ទន្ទឹមនឹងការងាររៀនសូត្រ និងការអប់រំបង្រៀនធម៌ដល់ពុទ្ធបរិស័ទព្រះ អង្គបានដឹកនាំកសាងនូវថាវរៈវត្ថុផ្សេងៗ ដើម្បីទុកជាប្រយោជន៍សំរាប់ជាតិ និង សាសនាបន្តទៀត ។ ដូច្នេះ សមិទ្ធិផលទាំងឡាយ ដែលព្រះអង្គបានកសាងមានដូច តទៅនេះ :

❖ នៅវត្ត **តាមមង្គល** : បានក្រាលការ៉ូកសាង **បល្ល័ង្គ** និងកសាងព្រះ **ពុទ្ធបដិមា** ថែមទាំងដឹកនាំកសាងសាលាបឋមសិក្សារការកោងក្រៅបានបីខ្នង ព្រមទាំងតុកៅអី ផ្តើមកសាងនៅឆ្នាំ ១៩៨៣ ។

❖ នៅវត្ត **សុវណ្ណទតី** : បានកសាងស្រះទឹក-កុដិថ្ម ព្រមទាំងរៀបរយផ្ទៃដីក្នុងវត្តបានល្អប្រសើរទៀតផង ។

❖ នៅវត្ត **នន្ទមុនី** : ព្រះអង្គបានដឹកនាំកសាងសមិទ្ធិផលដូចតទៅ:

១- សាងសង់ខឿនព្រះវិហារ (ដោយលោក **ស្រី ជាសាធារណ៍** និងលោកស្រី **ម៉ុយ សារី**) ។

២- កុដិឈើ១ខ្នង ដោយមានលោក **ជា សារ៉ាត** អ្នកស្រី **តែ មានរ៉ុខ** និងពុទ្ធបរិស័ទ ។

៣- អាគារថៃវ២ខ្នង មាន១០បន្ទប់ កសាងដោយពុទ្ធបរិស័ទ១ខ្នង និងព្រឹទ្ធាចារ្យ **សេ ឡុម** ១ខ្នង ។

៤- អាគារសិក្សា ២ខ្នង ដោយសីលវន្ត **សេ ឈុន** ។

៥- អាគារសមាធិ ១ ជាន់ ដោយពុទ្ធបរិស័ទ មានលោក **ខែត ផេង** និងភរិយា ព្រមទាំងបុត្រជាដើម ។

៦- អាងទឹក ៦០M$^3$ x ២០M$^3$

❖ នៅវត្ត **ពុទ្ធមណ្ឌល** បានស្ថាបនាសមិទ្ធិផល ដូចតទៅ :

១- ជីកស្រះមានបណ្ដោយ ៨០ម៉ែត្រ ទទឹង ៦០ម៉ែត្រ ។

២- ព្រះវិហារបាន ៥០% ផ្ដើមកសាងឆ្នាំ ១៩៩៨

៣- ធម្មសភាបានរួចរាល់ជាស្ថាពរ ផ្ដើមកសាងពីឆ្នាំ ១៩៩៩

៤- ម៉ាស៊ីនភ្លើង១គ្រឿង ដែលមានកំលាំង៥០គីឡូវ៉ាត់ជារនៅឆ្នាំ១៩៩៩

៥- ផ្ទះបាយ និងឃ្លាំងសម្ភារៈរួចរាល់ជាស្ថាពរ ផ្ដើមកសាងនៅឆ្នាំ ២០០០

៦- ពង្រីកផ្ទៃដីពុទ្ធមណ្ឌលពី៦ហិកតាដល់១៥ហិកតាឆ្នាំ១៩៩៦-២០០០ ។

៧- ចាក់ដីបំពេញរណ្ដៅក្នុង៤ហិកតាគន្លះ (ឆ្នាំ១៩៩៨-២០០០) ។

៨- មហាកុដិ២ជាន់ ផ្ដើមកសាងពីឆ្នាំ ២០០០ ។

៩- សាលាឆាន់បានរួចរាល់ជាស្ថាពរ ផ្ដើមកសាងពីឆ្នាំ ២០០០ ។

១០- កុដិថ្ម១ខ្នង មាន២ជាន់ ៤បន្ទប់ ដោយថវិការបស់ព្រះអង្គផ្ទាល់ ។

១១- តូបស្លឹក៣៥០ខ្នង... ផ្ដើមកសាងពីឆ្នាំ ២០០០-២០០១ ។

១២- ផ្លូវថ្នល់ក្នុង និងក្រៅពុទ្ធមណ្ឌល ផ្ដើមកសាងឆ្នាំ ២០០០-២០០១

១៣- អាងទឹកចំណុះ ១០០០ $M^3$ និង ៥០០ $M^3$ ព្រមទាំងបណ្ដាញទឹក ភ្លើង កសាងនៅឆ្នាំ ២០០២ ។

១៤- ខ្លោងទ្វារ អង្គរធំ-បន្ទាយស្រី កសាងឆ្នាំ ២០០០-២០០១

១៥- បន្ទប់អនាម័យ២០ខ្នង ( ក្នុង១ខ្នងមាន៥បន្ទប់ ) ( ២០០១ )

១៦- ដងទង់ ១ គូ កសាងឆ្នាំ ២០០១

១៧- ព្រះពុទ្ធដិមា មុជ្ជលិន្ទ កសាងឆ្នាំ ១៩៩៩-២០០០

១៨- បណ្ណាល័យ ផ្តើមកសាងឆ្នាំ ២០០២

១៩- សាលាអប់រំ ផ្តើមកសាងពីឆ្នាំ ២០០២ ( កំពុងសាងសង់ )

២០- ផ្ទះភ្ញៀវ ផ្តើមកសាងឆ្នាំ ២០០២ ( កំពុងសាងសង់ )

២១- អាគារដាក់ម៉ាស៊ីនភ្លើងធំ-២៥០គីឡូវ៉ាត់

២២- សាលាវិបស្សនាសីលវ័ន្ត និងសីលវតី ផ្តើមកសាងនៅឆ្នាំ ២០០២ រហូត មកដល់បច្ចុប្បន្នមិនទាន់រួចរាល់នៅឡើយ ។

## ❖ ការងារបណ្តុះបណ្តាល និងអប់រំ

ដើម្បីបណ្តុះបណ្តាលសិស្ស និងអប់រំអោយបានទទួលនូវគុណភាពខ្ពស់ និងលទ្ធផលល្អនោះ ព្រះអង្គបានរៀបចំនូវគោលការណ៍ ដូចខាងក្រោម :

### ១- **ការចងក្រងនិងនិពន្ធសៀវភៅ**

ព្រះអង្គបានរៀបរៀង និងចងក្រងសៀវភៅ ហើយផ្សព្វផ្សាយជូនពុទ្ធបរិស័ទសំរាប់សិក្សា ដូចខាងក្រោម :

១- សមថ និងវិបស្សនាកម្មដ្ឋាន

២- សីលកថា សង្ខេប

៣- គោលធម៌ថ្នាក់បឋម

៤- គោលធម៌ថ្នាក់មធ្យម

៥- គោលធម៌ ថ្នាក់ឧត្តម

៦- បឋមវិបស្សនា ពិស្តារ

៧- គិរីមានន្ទសូត្រ

៨- បាដិហារិយបោសថ

៩- និយមសីល

១០- វិក្រិត្យការគរុកោសល្យ

១១- មនុស្សចង់បានអ្វី

១២- ធុតង្គ និង បរិវាស

១៣- មធ្យមវិបស្សនា ពិស្តារ

១៤- វិន័យសីល ១០

១៥- ឧត្តមវិបស្សនា ផ្នាទី១ +ទី២ ព្រះអង្គបានរៀបរៀងចប់ ហើយ ប៉ុន្តែមិនទាន់បោះពុម្ពនៅឡើយ ។

## ២. ការខារបណ្តុះបណ្តាល

ដើម្បីតម្រូវទៅតាមសេចក្តីត្រូវការរបស់ពុទ្ធបរិស័ទទូទាំងប្រទេស ដែលខ្វះខាតនូវគ្រូកម្មដ្ឋាននោះ ព្រះអង្គបានបណ្តុះបណ្តាលនូវគ្រូបង្គោល និងសិក្ខាកាម ដែលបានទទួលវិញ្ញាបនប័ត្រ មានចំនួន ២៤១០នាក់ ក្នុងនោះមាន :

ថ្នាក់ឧត្តមបានចំនួន...........១១រូប

ថ្នាក់មធ្យមបានចំនួន............៦១រូប

ថ្នាក់បឋមបានចំនួន....២៣៣៨រូប ។

## ៣. ការបង្កើតមជ្ឈមណ្ឌលវិបស្សនាធុរៈតាមបណ្តាខេត្ត និងការរៀបចំអោយមានប្រព័ន្ធគ្រប់គ្រងតាមលំដាប់ថ្នាក់មានដូចជា :

១- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្ត ក្រចេះ ( ថ្ងៃ២៦-០១-៩៩)

២-........................................ ខេត្ត តាកែវ ( ថ្ងៃ ១០-០២-៩៩)

៣-........................................ ក្រុងកែប ( ថ្ងៃ ១៨-០២-៩៩)

៤-........................................ ខេត្ត សៀមរាប ( ថ្ងៃ ២៣-០៧-៩៩)

៥-........................................ ខេត្ត ពោធិសាត់ ( ថ្ងៃ ២០-០៥-២០០០)

៦-........................................ ខេត្ត កំពង់ធំ ( ថ្ងៃ ៣១-០៨-២០០០)

៧-........................................ ក្រុងព្រះសីហនុ ( ថ្ងៃ ០៩-០៩-២០០០)

៨-........................................ រាជធានីភ្នំពេញ ( ថ្ងៃ ២២-១០-២០០០)

៩- មជ្ឈមណ្ឌលវិបស្សនាធុរៈ ខេត្ត កំពង់ឆ្នាំង (ថ្ងៃ ០២-១១-២០០០)

១០-............................ខេត្ត ស្វាយរៀង (ថ្ងៃ ២៨-១១-២០០១)

១១-............................ខេត្ត កំពត (ថ្ងៃ ៣០-០៣-២០០២)

១២-............................ខេត្ត ព្រៃវែង (ថ្ងៃ ២៤-០៦-២០០២)

១៣-............................ខេត្ត មណ្ឌលគិរី (ថ្ងៃ ១៥-១២-២០០២)

## ៤.ការបង្កើតគណៈកម្មាធិការនាយកដឹកនាំការសិក្សាបាន៤ខេត្តគឺ:

១- ក្រុងភ្នំពេញ វត្ត **ឧន្នមនុន្នី**

២-ខេត្តពោធិសាត់

៣-ខេត្តស្វាយរៀង

៤-ខេត្តតាកែវ ។

ក្រៅពីការផ្សព្វផ្សាយតាមរយៈសៀវភៅ និងការបង្កើតឱ្យមានមណ្ឌលវិបស្សនាធុរៈតាមបណ្ដាខេត្តក្រុងនានា សរុបមាន ១៧ខេត្ត ដែលមានអ្នកប្រតិបត្តិធម៌វិបស្សនាធុរៈប្រមាណជាង ៣០.០០០នាក់នោះ ព្រះអង្គបានផ្សព្វផ្សាយតាមរយៈវិទ្យុ ដែលមានពុទ្ធបរិស័ទស្ដាប់ស្ទើរតែពេញផ្ទៃប្រទេសទាំងមូលទៀតផង ។

## ❖ សមណៈស័ក្តិដែលព្រះអង្គទទួលបាន:

១-ពីឆ្នាំ ១៩៨៦ ត្រូវបានព្រះមហា សុមេធាធិបតី **ទេព វង្ស** តែងតាំងជាអធិបតីមជ្ឈមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅវត្ត **ឧន្នមុន្នី** ក្រុងភ្នំពេញ ។

២- ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៧ ត្រូវបានតែងតាំងអោយមានឋានៈជាព្រះធម្មវិបស្សនារាជាគណៈថ្នាក់ **ចត្វា** ។

៣- ថ្ងៃ ១៥ ខែ ធ្នូ ឆ្នាំ ២000 បានទទួលឋានៈ ជាអធិបតីពុទ្ធមណ្ឌល និងជាអគ្គនាយកវិបស្សនាធុរៈសិក្សា នៃព្រះរាជាណាចក្រកម្ពុជា ។

៤- ថ្ងៃ ២៦ ខែ កក្កដា ឆ្នាំ ២០០១ ត្រូវបានតែងតាំងអោយធ្វើជាព្រះឧបជ្ឈាយ៍ សំរាប់បំបួសកុលបុត្រ ។

ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ អធិបតីពុទ្ធមណ្ឌល និងអគ្គនាយកវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា តាំងពីទទួលបព្វជ្ជា រហូតបានទទួលឋានៈដ៏ខ្ពង់ខ្ពស់នេះ មានការព្យាយាម និងបំពេញតួនាទីរបស់ព្រះអង្គ ដើម្បីដឹកនាំពុទ្ធបរិស័ទឱ្យប្រតិបត្តិនូវសេចក្តីល្អ ពោលគឺដឹកនាំមហាជនឱ្យធ្វើសេចក្តីល្អសំរាប់ខ្លួន និងសង្គម ធ្វើចិត្តឱ្យបានស្ងប់ ប្រាសចាក **លោភៈ ទោសៈ** និង **មោហៈ** ព្រមទាំងធ្វើឱ្យមានបញ្ញាជាក់ច្បាស់ក្នុងសង្ខារទៀតផង ។ ពីមួយថ្ងៃទៅមួយថ្ងៃ តាំងពីព្រលឹមដល់ព្រលប់ ព្រះអង្គមិនដែលមានពេលសំរាកឡើយ ព្រះអង្គដើរតួនាទីស្ថាបនាសង្គម តាមរយៈការផ្សព្វផ្សាយព្រះធម៌ ព្រហ្មចរិយធម៌ដល់ពុទ្ធបរិស័ទស្ទើរតែគ្រប់ទីកន្លែងទាំងអស់ ដោយព្រះទ័យជ្រះថ្លាជាទីបំផុត។ តែជាអកុសល នៅថ្ងៃ ៦ កើត ខែ មាឃ ឆ្នាំ មមែ ចត្វាស័ក ព.ស ២៥៤៦ ត្រូវនឹងថ្ងៃ ០៧ ខែកុម្ភៈ ឆ្នាំ ២០០៣ វេលាម៉ោង ១:១១នាទីយប់ ព្រះអង្គក៏បានអនិច្ចធម្មក្នុង

ព្រះជន្មាយុ ៤៧ ព្រះវស្សា ដោយ **ឃាតកម្មមរណៈ** ធ្វើឱ្យពុទ្ធបរិស័ទ សិស្សគណ គ្រប់មជ្ឈដ្ឋាន ទូទាំងព្រះរាជាណាចក្រកម្ពុជា មានក្តីតក់ស្លុតរន្ធត់អួលអាក់រកអ្វីប្រៀបផ្ទឹមពុំបានឡើយ ។

**អស់លោក លោកស្រី ពុទ្ធបរិស័ទជាទីគោរព !**

យោងតាមសកម្មភាពរបស់ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** តាំងពីដឹងក្តីរហូតដល់ពេលអនិច្ចធម្មនេះបញ្ជាក់ថាព្រះអង្គគឺជាវីរៈសង្ឃ និងជាខេមរបុត្រដ៏ឆ្នើម ដែលបានលះបង់នូវព្រះកាយពល និងព្រះបញ្ញាញាណ ដើម្បីបុព្វហេតុជាតិ និង សាសនាគ្មានស្តាយស្រណោះឡើយ ។ តែអនិច្ចាព្រះអង្គបានទទួលអនិច្ចធម្ម ដោយ **អកាលមរណៈ** ធ្វើឱ្យយើងទាំងអស់គ្នាមានសេចក្តីទុក្ខក្រៀមក្រំ ស្រងូតស្រងាត់ជាទីបំផុត ។ ពីមុនមកយើងទាំងអស់គ្នាធ្លាប់បានបំពេញកុសលនៅទីនេះ ធ្លាប់មានភាពសោមនស្សរីករាយ ដោយបានជួបព្រះភ័ក្ត្រ ព្រះកាយវិការដ៏រស់រវើករបស់ព្រះអង្គ តែពេលនេះ ភាពរីករាយដែលមានពីអតីតកាល ប្រែក្លាយជាមានទឹកមុខស្រពាប់ស្រពោន ស្រយុតស្រយង់ ក្រៀមក្រំ ខ្លោចផ្សានៅក្នុងអារម្មណ៍ទៅវិញ ?

**អធុវំ មេ ជីវិតំ ធុវំ មេ មរណំ** ជីវិតរបស់មនុស្សទាំងឡាយមិនទៀង តែសេចក្តីស្លាប់របស់មនុស្សទៀងក៏ពិតមែនហើយ តែយើងទាំងអស់គ្នានៅមិនទាន់អស់ចិត្តនៅឡើយ ព្រោះមនោសញ្ចេតនា និងអារម្មណ៍របស់យើងទាំង

អស់គ្នាជាសិស្សគណ បាននឹងកំពុងជិតជាប់នូវព្រះកាយវិការ និងសកម្មភាពគ្រប់បែបយ៉ាងរបស់ព្រះអង្គដែលមានកន្លងមក ជាពិសេស កាលដែលធ្លាប់បានស្តាប់នូវឱវាទ និងដំបូន្មានដ៏ល្អរបស់ព្រះអង្គ ។ ការមិនបានជួបគ្នាក្នុងរយៈកាលខ្លីតែប៉ុណ្ណោះ ស្រាប់តែពេលនេះព្រះអង្គបានស្ថិតនៅក្នុងមឈ្ឈូសកញ្ចក់ លែងមានវាចាជាមួយនឹងយើងជាសិស្សគណទៅវិញ ។ ការទទួលអនិច្ចធម្មរបស់ព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ គឺជាការបាត់បង់នូវធនធានព្រះសង្ឃ ជាធម្មកោវិទមួយអង្គ ដែលក្នុងមួយជីវិតរបស់ព្រះអង្គបានលះបង់ និងបូជាព្រះកាយឧទ្ទិសចំពោះព្រះពុទ្ធសាសនា ដោយព្រះទ័យជ្រះថ្លាដ៏បរិសុទ្ធបំផុត ព្រមទាំងបានលះបង់នូវកំលាំងកាយ កំលាំងចិត្ត និងកំលាំងប្រាជ្ញា ដោយស្មោះក្នុងការបណ្តុះបណ្តាលចែករំលែកនូវចំណេះដឹង រំលែនាំសីលធម៌សង្គម មានព្រហ្មវិហារធម៌ ព្រមទាំងផ្តល់ភាពកក់ក្តៅ ដល់សិស្សគណទាំងអស់ស្ទើរតែគ្រប់មជ្ឈដ្ឋានទូទាំងព្រះរាជាណាចក្រកម្ពុជាទាំងមូល ។ ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំ ចេះតែឆ្ងាយទៅៗ មានន័យថាព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ បានឃ្លាតឆ្ងាយពីយើង ឬថាយើងទាំងអស់គ្នាឃ្លាតពីព្រះអង្គជារៀងរហូតគ្មានពេល គ្មានថ្ងៃខែឆ្នាំណា នឹងបានជួបគ្នាទៀតឡើយ ។

អ្វីដែលនៅសេសសល់នោះ មានតែអនុស្សាវរីយ៍ដែលព្រះអង្គធ្លាប់មានជាមួយយើង ពាក្យប្រៀនប្រដៅខ្លះៗ ទីកន្លែងដែលព្រះអង្គធ្លាប់គង់នៅ និងសំដីដែល

ព្រះអង្គធ្លាប់សាសងជាមួយយើង ជាពិសេសស្រមោលអតីតកាលទាំងប៉ុន្មាន ដូចជាស្នាព្រះហស្ថ និងសមិទ្ធិផលនានាដែលព្រះអង្គបានកសាង នឹងមកពញ្ញាក់ និងដាស់នូវសោតិន្ទ្រិយារម្មណ៍ និងមនោរម្មណ៍របស់យើងទាំងអស់គ្នាឱ្យនឹកហើយនឹកទៀត នឹកមិនភ្លេចនូវអ្វីដែលធ្លាប់មានតែប៉ុណ្ណោះ ។

ព្រះកាយរបស់ព្រះអង្គបានបាត់ទៅមែនពិត ប៉ុន្តែអ្វីដែលជាអមតៈសំរាប់យើងទាំងអស់គ្នាចងចាំគឺ កេរ្តិ៍ឈ្មោះ កិត្តិយស គុណធម៌ និងស្នាព្រះហស្ថរបស់ព្រះអង្គនៅតែមានជីវិតរស់រវើកជានិច្ច ។

សូមឱ្យវិរៈភាព និងឧត្តមគតិរបស់ព្រះសព ដែលបានបូជា និងលើកស្ទួយព្រះពុទ្ធសាសនា និងសង្គមជាតិ ស្ថិតនៅរហូតក្នុងចិត្តគំនិតរបស់ប្រជាពលរដ្ឋខ្មែរ និងសិស្សគណទាំងឡាយ ដើម្បីបុព្វហេតុជាតិ សាសនា និងសេចក្តីសុខ សន្តិភាព វឌ្ឍនភាពសំរាប់សង្គមជាតិទាំងមូល ជារៀងរហូតតទៅ ។

អវសាននេះ យើងទាំងអស់គ្នា សូមសំដែងនូវគារវកិច្ច និងកតញ្ញូតាធម៌ ដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះវិញ្ញាណក្ខន្ធព្រះសព និងសូមឱ្យសេចក្តីប្រាថ្នាជាពុទ្ធភូមិរបស់ព្រះសពបានសំរេចតាមសេក្តីប៉ងប្រាថ្នាកុំបីអាក់ខានឡើយ ។ មួយវិញទៀត សូមឧទ្ទិសកុសលប្រគេន ព្រះវិញ្ញក្ខន្ធរបស់ព្រះធម្មវិបស្សនា ព្រះសពព្រះអង្គ **សំ ប៊ុនធឿន** កេតុធម្មោ បានទៅប្រតិស្ថានក្នុងសុគតិភពកុំបីអាក់ខានឡើយ ។

ដោយអំណាចនៃគុណធម៌នេះ សូមឱ្យសព្វសត្វទាំងឡាយក្នុងលោក បញ្ឈប់នូវពៀរវេរានិងគ្នា ឈប់ព្យាបាទគ្នា ចាប់ពីពេលនេះតទៅ និងសូមឱ្យលោកទាំងមូលបានប្រកបដោយសុខសន្តិភាពសមតាមបំណងរបស់ខ្លួន កុំបីអាក់ខានឡើយ ។!

* *

*

ប្រមូលរៀបរៀងចងក្រងដោយ

គណៈកម្មាធិការពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា

ស្ថិតនៅខាងលិចភ្នំអង្គរស្ស ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ។

## ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ

**សេចក្តីផ្តើម** :ក្នុងសម័យសិក្ខាសាលាជាតិដែលស្តីអំពី " ស្ថានភាពសាសនានៅកម្ពុជាបច្ចុប្បន្ន " ដែលប្រព្រឹត្តទៅនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០២ រៀបចំដោយវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិតសភាកម្ពុជា ដោយមានបំណងៈ

-ធ្វើតុល្យការក្នុងប្រទេស ។

-សិក្សាពីដំណើរវិវត្តន៍នៃសាសនានីមួយៗ "ព្រះពុទ្ធសាសនា និងសាសនាដទៃ" ។

-ចែករំលែកពត៌មាន បទពិសោធន៍ និងទស្សនៈ រវាងមន្ត្រីនៃស្ថាប័នពាក់ព័ន្ធ និងអ្នកតំណាងសាសនានានៅកម្ពុជា ។

-ស្វែងរកដំណោះស្រាយ និងទិសដៅនៃសាសនា ។

-យល់កត្តាវិជ្ជមាន និងអវិជ្ជមាននៃសាសនា ។

-សកម្មភាពព្រះពុទ្ធសាសនា និងសាសនាដទៃនៅកម្ពុជាបច្ចុប្បន្ន ។

ខ្ញុំសូមលើកឡើងនូវប្រធានបទអន្តរាគមន៍ ដែលមានចំណងជើងថា "ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ" ។

## មូលហេតុដែលនាំឱ្យព្រះពុទ្ធសាសនា បានទៅជាសាសនារបស់រដ្ឋ

មូលហេតុដែលនាំឱ្យខ្មែរបានកំណត់ក្នុងច្បាប់រដ្ឋធម្មនុញ្ញថា ព្រះពុទ្ធ-សាសនាជាសាសនារបស់រដ្ឋនោះ ខ្ញុំសូមលើកយកខ្លឹមសាររបស់ព្រះពុទ្ធសាសនាមកបកស្រាយ ដោយសេចក្តីសង្ខេបដូចតទៅ:

ពុទ្ធសាសនាចែកចេញជាពីរបទគឺ : ពុទ្ធស្ស និងសាសនា បានជាពុទ្ធសាសនា ។

សាសនាមានន័យថា ពាក្យប្រៀនប្រដៅ ពុទ្ធស្សរបស់ព្រះពុទ្ធ រួមសេចក្តីមក ពុទ្ធសាសនាប្រែថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធនោះ មានចំនួន៨៤.០០០ធម្មក្ខន្ធគឺ វិន័យមាន ២១.០០០ធម្មក្ខន្ធ ព្រះសូត្រមាន ២១.០០០ធម្មក្ខន្ធ ព្រះអភិធម្មមាន ៤២.០០០ធម្មក្ខន្ធ។ ពាក្យប្រៀនប្រដៅទាំងអស់នេះ បើបំព្រួញឱ្យខ្លីមានត្រឹមតែ៣បទ :

១- **សព្វបាបស្សអករណំ**: កិរិយាមិនធ្វើនូវអំពើបាបទាំងពួង

២- **កុសលស្សូបសម្បទា** : កិរិយាបំពេញនូវអំពើល្អ ។

៣-**សចិត្តបរិយោទបនំ** : កិរិយាជម្រះចិត្តឱ្យស្អាតផូរផង់ ។

១.**សព្វបាបស្សអករណំ** : កិរិយាមិនធ្វើនូវអំពើបាបទាំងពួង មានសេចក្តីថា បាបជាភាសាខ្មែរ ដែលក្លាយមកពីភាសាបាលី បាបៈ មានន័យថា អំពើដ៏លាមក

ឬ អំពើថោកទាប ។ អំពើបាបនេះ គឺជាអំពើមួយដែលនាំឱ្យអសកម្មដល់សង្គម ធ្វើឱ្យសង្គមដល់នូវសេចក្តីវិនាស គ្រប់បែបយ៉ាង ។ តែក្នុងទីនេះ សូមលើកយក តែបាបមានចំនួន១០យ៉ាងមកបកស្រាយដូចតទៅនេះ :

-បាណាតិបាត : សម្លាប់សត្វ ។

មានសេចក្តីថា ធ្វើជីវិតរបស់សត្វទូទៅឱ្យដល់នូវសេចក្តីវិនាស ដោយ ប្រើសព្វាវុធផ្សេងៗមាន ដំបង ដាវ លំពែង កាំភ្លើង គ្រាប់មីន គ្រាប់បែក កាំជ្រួច បរមាណូ និងនុយក្លេអែរជាដើម ។ ពពួកសត្វ ដែលបានទទួលរងគ្រោះវិនាសកម្ម គ្រប់បែបយ៉ាង ដោយអំពើហិង្សារបស់ជនដទៃ ក៏ដល់នូវសេចក្តីទុក្ខធំ ។ សត្វណា បរាជ័យក៏ស្លាប់ទៅឬពួនសម្ងំចងកំហឹង ដើម្បីសងសឹកដល់សត្វដែលឈ្នះនោះ វិញ ។ សត្វណា ដែលបានជ័យជំនះក៏ដល់នូវភាពរីករាយសប្បាយ ក៏ប៉ុន្តែសេចក្តី ភ័យព្រួយក៏នឹងកើតឡើងដល់សត្វនោះ ព្រោះហេតុតែខ្លាចខ្លួនចាញ់គេវិញ ។ ម៉្លោះ ហើយសត្វទាំងពីរពួក គឺអ្នកចាញ់ និងអ្នកឈ្នះក៏នៅតែចងពៀរ ផ្ចួនផ្ចាគ្នាទៅវិញ ទៅមករហូតដល់សេចក្តីវិនាសដ៏ធំកើតឡើងក្នុងលោក ។ ទៅក្នុងអនាគត ព្រះពុទ្ធ ជាអម្ចាស់ លោកបានត្រាស់សម្តែងអំពីទោសនៃការសម្លាប់នោះ ដោយមាន សេចក្តីថា កាលបើមនុស្សនៅតែសម្លាប់ គ្នាទៅវិញទៅមក មនុស្សក្នុងលោកទៅ ក្នុងអនាគតកាលនឹងមានអាយុខ្លីចុះ រហូតដល់ស្ត្រីមានអាយុត្រឹម៥ឆ្នាំ មានប្តី មនុស្សក្នុងសម័យនោះនឹងអាចរស់នៅក្នុងសង្គមបាន ត្រឹមអាយុ១០ឆ្នាំស្លាប់ ។

-**អទិន្នាទាន** : កិរិយាកាន់យកទ្រព្យដែលម្ចាស់គេមិនឱ្យដោយកាយ ឬ វាចា ។

សេចក្ដីថា អទិន្នាទាន គឺជាអំពើចោរកម្ម ដែលមនុស្សក្នុងសង្គម គួរភ័យខ្លាច ។ អំពើចោរកម្មមានន័យថា អំពើលួចឆក់ កេងប្រវ័ញ្ច ប្លន់ ចាប់ជម្រិតជនដទៃ រឹបអូសយកទ្រព្យសម្បត្តិ។ ព្រះពុទ្ធទ្រង់ បានត្រាស់អំពីប្រភេទ នៃការលួចថា ទោះជាបុគ្គលកាន់យកទ្រព្យគេដែលម្ចាស់មិនបានដឹងក្ដី គម្រាមកំហែងប្លន់យកទ្រព្យក្នុងទីចំពោះមុខគេក្ដី ប្រកបអាជីវកម្មដោយការកែបន្លំដោយនាឡិតៅ ភ្នែកជញ្ជីង ។ល។ ក្ដី ឈ្មោះថា ធ្វើចោរកម្មដូចគ្នា ។

-**កាមេសុមិច្ឆាចារ** : កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

សេចក្ដីថា បុរសទាំងឡាយដែលបានចាប់បង្ខំបំពានរំលោភលើស្ត្រីដទៃដែលមិនមែនជាភរិយារបស់ខ្លួនក្ដី ស្ត្រីទាំងឡាយដែលក្បត់ចិត្តប្ដីយកជនដទៃ ធ្វើជាស្វាមីរបស់ខ្លួនក្ដី ឈ្មោះថា ប្រព្រឹត្តខុសក្នុង កាមដូចគ្នា ។

-**មុសាវាទ** : ពោលពាក្យកុហក ។

មានសេចក្ដីថា និយាយកុហកទាំងដឹងខ្លួន ឃើញពោលថាមិនឃើញ មិនឃើញពោលថាបានឃើញ បានឮពោលថាមិនឮ មិនឮពោលថាឮ បានប៉ះពោលថាមិនបានប៉ះប៉ះហើយពោលថាមិនបានប៉ះទៅវិញបានដឹងហើយ ពោលថា

មិនដឹង មិនដឹងពោលថាដឹង ។ អាការៈទាំងអស់នេះឈ្មោះថា និយាយកុហក

ទាំងអស់ ។

-**បិសុណាវាចា** : និយាយញុះញង់ ។

មានសេចក្តីថា អុជអាលឱ្យជនដទៃចាប់តាំងពីពីរនាក់ឡើង ទៅបែក

បាក់សាមគ្គីគ្នារហូតដល់ ពិភពលោកមួយមានការប្រេះស្រាំ ចែកគ្នាជាបក្សពួក

ប្រកាន់ពូជសាសន៍វណ្ណៈភេទរហូតដល់បង្កសង្គ្រាម បង្កើតឡើងនូវមហន្តរាយធំ ។

-**ផរុសវាចា** : និយាយពាក្យអាក្រក់ សេចក្តីថា ជេរប្រទេច

ផ្តិះផ្តៀល ប្រើពាក្យចាក់ដោត ប្រមាថមើលងាយ ធ្វើឱ្យជនដទៃដល់នូវសេចក្តី

ក្រោធ កើតទុក្ខទោមនស្ស ឈឺចាប់បង្ហូរទឹកភ្នែក ឬ ច្រឡោតខឹងតបវិញ ។

-**សម្ផប្បលាប** : និយាយពាក្យរោយរាយឥតប្រយោជន៍ ។

មានសេចក្តីថា ប្រើប្រាស់សម្តីគ្មានខ្លឹមសារដល់សង្គម ជាពាក្យកំប្លុក

កំប្លែង កែឆ្នៃពាក្យដែលមានខ្លឹមសារឱ្យទៅជាពាក្យឥតខ្លឹមសារទៅវិញ ឬ រឿង

ឥត ខ្លឹមសារប្រឌិតឱ្យមានខ្លឹមសារឡើង ដើម្បី កកាយយកផលប្រយោជន៍របស់

ជនដទៃមកធ្វើជារបស់ខ្លួនវិញ (អាត្មានិយម) ។

-**អភិជ្ឈា** : សំឡឹងរំពៃចង់បានទ្រព្យសម្បត្តិជនដទៃមកធ្វើជាទ្រព្យ

របស់ខ្លួន ។

មានសេចក្ដីថា ចិត្តចង់បាន ដែលប្រកបដោយសេចក្ដីលោភលន់ហួសពេក មិនបានគិតដល់ផល ប្រយោជន៍ជនដទៃ គឺគិតត្រឹមតែផលប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ។ សកម្មភាពទាំងអស់ ទោះជាធ្វើដោយកាយក្ដី វាចាក្ដី ក៏សុទ្ធតែមានទិសដៅតែមួយគត់ គឺបម្រើផលប្រយោជន៍ខ្លួន មិនបានគិតដល់ផលប្រយោជន៍ជនដទៃ ឬ ប្រយោជន៍រួមឡើយ(លួចជាតិ) ។

**-ព្យាបាទ** : ចងគំនុំគុំគួន។

មានសេចក្ដីថា កំហឹងដែលកើតឡើងក្នុងចិត្ត ព្រោះជួបនឹងអារម្មណ៍មិនជាទីគាប់ចិត្ត ខុសគោលបំណងរបស់ខ្លួន ក៏មានគំនិតផ្ដួចផ្ដើមឡើងចងអាឃាតប្រាថ្នាចង់ឱ្យសត្វដទៃក្នុងលោកដល់នូវសេចក្ដីវិនាស មានវិនាសទ្រព្យសម្បត្តិប្រពន្ធ-កូន ក្រុមញាតិ សក្តិយស រហូតដល់អាយុជីវិត។

**-មិច្ឆាទិដ្ឋិ** : ទស្សនៈឃើញខុស ។

មានសេចក្ដីថា យល់ខុសប្រាសចាកគន្លងធម៌ មិនជឿបុណ្យបាប គុណនិងទោស ឱ្យផលជាសុខជាទុក្ខ ដូចជាបុគ្គលយល់ឃើញថា ការសង្គ្រោះជនដទៃ(មនុស្សធម៌)គ្មានប្រយោជន៍ក្នុងសង្គម ឬ យល់ ឃើញថា ការស៊ីសំណូកសូកប៉ាន់កេងបន្លំ កាប់សម្លាប់ ដែលខុសចាកច្បាប់ផ្លូវលោក មានច្បាប់រដ្ឋធម្មនុញ្ញជាដើម ឬ ច្បាប់ផ្លូវធម៌ ជាអំពើមានប្រយោជន៍ដូច្នេះ។ល។

សកម្មភាពទាំង១០ ដែលបានពោលហើយខាងលើ ជាសកម្មភាពជួរចត់ល្វីងជូរ ធ្វើឱ្យសង្គមគ្មានអត្ថិភាព។ មនុស្សទាំងឡាយក្នុងលោកគួរ តែវៀរបង់ កុំធ្វើនូវអំពើអាក្រក់ទាំង១០យ៉ាងនេះ ជាការប្រពៃណាស់ ព្រោះថាមនុស្សក្នុងលោក កាលបើមិនបានធ្វើនូវអំពើបាបតែងរស់នៅ ជាសុខដោយគ្មានពៀរ។

២.កុសលស្សូបសម្បទា : បំពេញនូវកុសលធម៌ សេចក្តីថា កុសលធម៌ គឺជាធម៌ល្អជាគួបុណ្យ ប្រាសចាកបាប ជាអំពើមួយនាំមក នូវការអភិវឌ្ឍន៍ គ្រប់បែប យ៉ាងដល់សង្គម។ អំពើល្អនោះមានច្រើន តែក្នុងទីនេះ សូមលើកយកតែ១០យ៉ាងមកបកស្រាយ មានដូចតទៅ:

-**ទាន** : ការចែករំលែកទ្រព្យសម្បត្តិខ្លួនផ្ទាល់ កសាងសង្គម មានការកសាងផ្លូវថ្នល់ មន្ទីរពេទ្យ សាលារៀន ជីកស្រះ ជីកអណ្តូង ដាំព្រៃឈើ សួនច្បារ ចែកអំណោយដល់ជនក្រីក្រ កសាងវត្ត ឬ អារាម មានសង់កុដិ ព្រះវិហារ និងសមិទ្ធិផលផ្សេងៗ ឬ ធ្វើបុណ្យកុសលនានាក្នុងព្រះពុទ្ធសាសនា មានបុណ្យបច្ច័យបួនជាដើម ។

-**សីល** : ចរិយាល្អ ឬកពារសណ្តាប់ល្អ ការរស់នៅប្រកបដោយសុជីវធម៌ ធ្វើសេចក្តីសង្រួមកាយ វាចាចិត្ត មិនសាងនូវអំពើអាក្រក់ទាំង៥ មានកិរិយាសម្លាប់ជនដទៃ ធ្វើចោរកម្ម ចាប់ប្រពន្ធ-កូនជនដទៃ ឬ ផិតប្តី ប្រព្រឹត្តធ្វើ

ជាស្រីបេស្យាផ្កាមាស ពោលពាក្យភូតភរ និងផឹកស្រវឹង ដែលជាអំពើមួយនាំឱ្យសង្គម ដល់នូវភាពអាប់អួរ ។

**_តាទនា** : អប់រំចិត្តគំនិត កសាងចិត្តឱ្យស្លូតបូត ស្មោះត្រង់លះបង់នូវសេចក្តីលោភលន់ ខឹងប្រទូស្ស និងការហួងហែងប្រកាន់ខ្លួន ប្រកាន់វណ្ណៈ ពូជសាសន៍ ជាតិត្រកូល ធ្វើខ្លួនឱ្យចេះរស់នៅស្រប តាមសង្គម ។

**_អបចាយនៈ** គោរពចាស់ទុំត្រកូលរៀមច្បង មានភាពទន់ភ្លន់ចំពោះមនុស្សសត្វ មិនរើសអើង មិនប្រកាន់វណ្ណៈ មានភាពរាក់ទាក់នឹងជនដទៃ ដូចលើកដៃសំពះគោរពមាតា-បិតា គ្រូអាចារ្យ ជាដើម ។

**_វេយ្យាវច្ចករ** : ជួយចាត់ចែងខ្វល់ខ្វាយក្នុងកិច្ចការរបស់ជនដទៃ មានធ្វើទីជម្រកឱ្យកុមារកំព្រាជ្រកនៅឬជួយចាត់ចែងពិធីការផ្សេងៗ មានទទួលបដិសណ្ឋារៈចំពោះជនដែលមានឥស្សរយស ឬ ព្រះសង្ឃដែលអញ្ជើញ ឬ និមន្តមកក្នុងពិធីណាមួយ ឬ ក៏ជួយចាត់ចែងបុណ្យទានរបស់មាតា-បិតា ឬ ជនដទៃជាដើម ។

**_ទេសនា** : ទេសនា បង្រៀន ពន្យល់ ឱ្យដំបូន្មាន ដឹកនាំជនដទៃឱ្យមានការចេះដឹងស្គាល់ហេតុល្អ ហេតុអាក្រក់ ស្គាល់គុណ ស្គាល់ទោស ស្គាល់បុណ្យ ស្គាល់បាបជាដើម ។

-**ធម្មស្សវន** : កិរិយាស្តាប់នូវព្រះធម៌ ស្តាប់ពាក្យប្រៀនប្រដៅដ៏ល្អៗរបស់គ្រូមាតា-បិតាចាស់ព្រឹទ្ធាចារ្យឬព្រះសង្ឃ ។ល។ មួយវិញទៀត លោកអ្នកពោលសម្តែងបង្រៀន ឬ ឱ្យដំបូន្មានក្នុងការកសាងខ្លួនឱ្យ បានល្អជាដើម ។

-**បត្តិទាន** : ចែកបុណ្យដល់ជនដទៃ បុគ្គលកាលបើបានធ្វើនូវបុណ្យមានបុណ្យបច្ច័យ៤ជាដើម ហើយញ៉ាំងជនដទៃឱ្យអនុមោទនាត្រេកអរចំពោះបុណ្យនោះ តួយ៉ាងដូចពិធីបុណ្យក្នុងព្រះពុទ្ធ សាសនាម្តង១ កាលបើគេបាន ធ្វើបុណ្យរួចហើយ គេក៏សូត្រធម៌ឧទ្ទិសកុសល ឬ ផ្សាយមេត្តាចិត្តដល់ពពួកសត្វដទៃព្រោះចង់ឱ្យពពួកសត្វនោះបានដល់នូវសេចក្តីសុខចម្រើនអាការៈ ដែលចែកបុណ្យនោះឯងហៅថា **បត្តិទាន** ។

-**បត្តានុមោទនា** : ត្រេកអរនឹងបុណ្យដែលគេចែកហើយដល់ខ្លួន។ សេចក្តីថា បុណ្យទាំងឡាយ មានបុណ្យបច្ច័យ៤ជាដើម ដែលគេបានធ្វើហើយគេចែកបុណ្យនោះដល់ខ្លួន ហើយខ្លួនក៏បានទទួលត្រេកអរស្វាគមន៍ រាក់ទាក់ រីករាយ ស្រោះស្រាយ អនុមោទនាចំពោះបុណ្យនោះ អាការៈដែលបុគ្គលត្រេកអរ អនុមោទនាចំពោះបុណ្យនោះឯង ហៅថា **បត្តានុមោទនា** ។

-**ទិដ្ឋុជុកម្ម ករោតិ** : ធ្វើទិដ្ឋិឱ្យត្រង់ ។

មានសេចក្តីថា ការយល់ឃើញត្រូវ គឺយល់ឃើញថា អ្នកធ្វើអំពើបាបរមែងសៅហ្មងដោយខ្លួនឯង អ្នកធ្វើអំពើល្អរមែងបរិសុទ្ធដោយខ្លួនឯង សេចក្តី

បរិសុទ្ធនិងមិនបរិសុទ្ធ គឺខ្លួនឯងជាអ្នកធ្វើខ្លួនឯង ទើបសម្អាតខ្លួនបាន ជនដទៃមិនអាចសម្អាតឱ្យខ្លួនបានឡើយ ។

-អ្នកធ្វើអំពើល្អរមែងទទួលផលជាសុខ រីឯអ្នកធ្វើអំពើអាក្រក់រមែងទទួលផលជាទុក្ខ ។ ដំណើរ ដែលយល់ឃើញយ៉ាងនេះ ហៅថា ធ្វើទិដ្ឋិឱ្យត្រង់ ។

## ឧសុនោះកម្មផល

មនុស្សទាំងឡាយក្នុងលោកដែលកំពុងសោយនូវសេចក្តីទុក្ខ ឬ សេចក្តីសុខ មានអាយុវែង ឬ ខ្លី បរិបូណ៌ដោយភោគ ឬ ទាល់ក្រ មានប្រាជ្ញាឬគ្មានប្រាជ្ញាជាដើម ។ល។ ដំណើរដែលមនុស្សទាំងឡាយ បានជួបនូវហេតុបែបនេះ ជួនកាលកម្មអតីតឱ្យផល ជួនកាលកម្មបច្ចុប្បន្នជាតិនេះឱ្យផលក៏មាន ។

-កម្មអតីតឱ្យផលនោះ គឺយ៉ាងដូចមនុស្សកើតក្នុងត្រកូលទាល់ក្រ គថ្លង់ ខ្វាក់ ខ្វិន ពីកំណើត ឬ អាយុវែង-ខ្លី ជាដើម ។

-កម្មបច្ចុប្បន្នជាតិនេះឱ្យផលនោះ គឺយ៉ាងដូចមនុស្សខ្លះបានទ្រព្យពីមាតា-បិតា ឬ ក៏ជនណាម្នាក់ ហើយខ្លួនយកទ្រព្យនោះទៅចំណាយលើអំពើអត់ប្រយោជន៍ មានលេងល្បែងស៊ីសង លេងស្រី លេងស្រាជាដើម រហូតដល់អស់ទ្រព្យ ។ ការអស់ទ្រព្យនោះ មិនមែនមកពីកម្មជាតិមុនឱ្យផលឡើយ គឺប្រាកដជាកម្មជាតិនេះឯងឱ្យផល ។

ជនណាប្រកបដោយអង្គ៤ គឺ សុ ចិ បុ លិ ជននោះនឹងក្លាយទៅជាអ្នកប្រាជ្ញបានដោយធូរ ជនណាប្រាសចាកអង្គ៤ គឺ សុ ចិ បុ លិ ជននោះនឹងក្លាយទៅជាអ្នកប្រាជ្ញដូចម្តេចកើត ?

-**សុ** : បានដល់សុត្ត ខំប្រឹងសិក្សា រៀនសូត្រ ទន្ទេញ ស្តាប់ ឱ្យបានច្រើន ។

-**ចិ** : បានដល់ចិន្ត ប្រឹងគិតពិចារណានូវមេរៀនដែលខ្លួន បានទទួលពីគ្រូ ហើយធ្វើការពិចារណា ឱ្យយល់ច្បាស់លាស់ ដើម្បីបំបាត់សេចក្តីសង្ស័យ ។

-**បុ** : បានដល់បុច្ឆា សាកសួរគ្រូនូវមេរៀនដែលខ្លួនគិតពិចារណាហើយ១មានសេចក្តីងឿងឆ្ងល់ ។

-**លិ** : បានដល់លិខិត កត់ត្រាចំណាំទុកនូវមេរៀនដែលខ្លួនបានយល់ហើយមិនឱ្យភ្លេចទៅវិញ ។ អាការៈដែលមនុស្សចេះ ឬ ល្ងង់តាមបែបនេះ ហៅថាកម្មបច្ចុប្បន្នជាតិនេះឱ្យផល ។

កាលបើធ្វើសេចក្តីយល់តាមដំណើរពិត ដូចបានពោលហើយខាងលើដូច្នេះហៅថា ទិដ្ឋជុកម្មករោតិ ។

កុសលធម៌ ដែលបានពោលហើយខាងលើនេះ មនុស្សទាំងឡាយគួរខំប្រឹងកសាងឱ្យកើតមានឡើង ព្រោះជាហេតុនាំឱ្យមានការអភិវឌ្ឍន៍ដល់សង្គម ឬ ប្រទេសជាតិ ។

៣.សចិត្តបរិយោនបនំ : កិរិយាជម្រះចិត្តឱ្យផូរផង់ ។

មានសេចក្តីថា ចិត្តជាធម្មជាតិមួយមានសភាពប្លែងប្លោង ឆាប់កម្រើក ញាប់ញ័រ លំបាករក្សា ផ្ចុញផ្ចាល់បានដោយកម្រ រមែងតែងរមៀលធ្លាក់ចុះក្នុងកាមារម្មណ៍ តែងប្រឡាក់ដោយកិលេសរឿយៗ។ ព្រះពុទ្ធ ទ្រង់ត្រាស់ថា "ចិត្តជាធម្មជាតិធំជាងគេ អ្វីៗទាំងអស់សម្រេចមកតែពីចិត្ត" តួយ៉ាងដូចនៅក្នុងពិភពលោកយើងនេះ មនុស្សទាំងអស់ដែលមានមុខរបររកស៊ីខុសៗគ្នា អ្នកខ្លះធ្វើគ្រូបង្រៀន ពេទ្យ យោធា ប៉ូលីស មន្ត្រីរាជការ ធ្វើស្រែចំការ ពាណិជ្ជកម្ម ឬ ប្រព្រឹត្តធ្វើនូវអំពើខុសច្បាប់ មានធ្វើចោរកម្ម ប្រព្រឹត្ត បេស្យាចារជាដើម សុទ្ធតែមានចិត្តដឹកនាំឱ្យធ្វើទាំងអស់ ។

រួមសេចក្តីមក ពិភពលោកបានសេចក្តីទុក្ខ ឬ សេចក្តីសុខ គឺមកតែអំពីចិត្ត ក្នុងសម័យណាចិត្ត ប្រឡាក់ដោយកិលេសគឺ លោភៈ ទោសៈ មោហៈ ក្នុងសម័យនោះពួកមនុស្សសាងតែអំពើបាប មានកាប់សម្លាប់ជាដើម ។ ក្នុងសម័យណាដែលចិត្តតក់ស្លុតខ្លាចនឹងអំពើបាប ក្នុងសម័យនោះមនុស្សកសាងនូវអំពើល្អ (បុណ្យ)។ កាលបើមនុស្សសាងអំពើបាបផង អំពើបុណ្យផង ដូច្នេះ សេចក្តីទុក្ខ និងសេចក្តីសុខក៏នឹងកើត មានពិតប្រាកដដល់មនុស្សទាំងនោះ ព្រោះសេចក្តីទុក្ខជាផលនៃអំពើបាប សេចក្តីសុខជាផលនៃអំពើបុណ្យ។

ព្រះពុទ្ធទ្រង់ត្រាស់ថាកាលបើមនុស្សចង់បានតែសេចក្តីសុខដល់ខ្លួនមនុស្ស

គប្បីទូន្មានចិត្តរបស់ខ្លួនឱ្យស្ងប់ ។ពុទ្ធដីកាថា "ចិត្តំ ទន្តំ សុខាវហំ" ចិត្តដែលជនទូន្មានល្អហើយតែងនាំសេចក្តីសុខមកឱ្យ ។ "ចិត្តំ គុត្តំ សុខាវហំ" ចិត្តដែលជនគ្រប់គ្រងល្អ ហើយតែងនាំសេចក្តីសុខមកឱ្យ ។ កាលបើមនុស្សក្នុងលោកគ្រប់រូបបានអប់រំទូន្មានចិត្តដូចៗគ្នា ពិភពលោកត្រូវបានទទួលនូវ សុខសន្តិភាពដោយពិត ព្រោះគ្មានមនុស្ស មានចិត្តអាក្រក់ បង្កនូវអំពើបាបកម្ម ដែលនាំឱ្យអសកម្មដល់សង្គមទូទៅ ។

ដោយសេចក្តីដូចបានពោលហើយខាងលើ ទើបព្រះពុទ្ធទ្រង់ទូន្មានប្រៀនប្រដៅឱ្យសត្វលោក ខំប្រឹងតែជម្រះចិត្តរបស់ខ្លួនឱ្យស្អាតផូរផង់ឡើង ។

ដោយមូលហេតុថា ព្រះពុទ្ធសាសនាជាសាសនាសម្តែងអំពីកម្ម និងផលជាដំបូន្មានបែបវិទ្យាសាស្ត្រ មានហេតុផលគួរឱ្យកត់សម្គាល់បាន ទើបប្រជាពលរដ្ឋខ្មែរតាំងពីសម័យបុរាណមក ក៏បានទទួលយកនូវព្រះពុទ្ធសាសនា មកធ្វើជាទីពឹងរៀង១ខ្លួន ។ ព្រះពុទ្ធសាសនាបានជ្រាបចូលក្នុងសន្តាន ចិត្តនៃកូនខ្មែរគ្រប់ៗរូប ទាំងព្រះមហាក្សត្រ ទាំងមន្ត្រីរាជការ រហូតដល់ប្រជាពលរដ្ឋសាមញ្ញទូទៅ ដោយហោចទៅ ខ្មែរមានចំនួន៩៥ភាគរយ កាន់នូវព្រះពុទ្ធសាសនានាបច្ចុប្បន្នកាលនេះ ។ ព្រះពុទ្ធសាសនា បានក្លាយទៅជាខឿនវប្បធម៌របស់ខ្មែរតួយ៉ាងដូចជា ភាសាសម្រាប់និយាយស្តី អក្សរសាស្ត្រជាតិស្ទើរតែទាំងអស់

ដែលមានកំណើតក្លាយចេញពីភាសាបាលី និងសំស្ក្រឹត ដែលជាភាសាសម្រាប់ប្រើប្រាស់ក្នុងព្រះពុទ្ធសាសនា ។

ម្យ៉ាងទៀតព្រះពុទ្ធសាសនា គឺជារូបមន្តដ៏សំខាន់បំផុតរបស់ខ្មែរក្នុងការកសាងសន្តិភាព សម្រាប់ប្រទេសជាតិ។ ខ្មែរបើគ្មានព្រះពុទ្ធសាសនាទេ មិនអាចស្វែងរកសន្តិភាពសម្រាប់ប្រទេសបានឡើយ ជាពិសេស ថ្មីៗនេះ ក្រោយពីខ្មែរបានកើតសង្គ្រាមបង្ហូរឈាមរវាងគ្នានឹងគ្នា អស់រយៈពេលជាងពីរទសវត្សរ៍មក ខ្មែរបានរកឃើញរូបមន្តសន្តិភាពមួយ តាមរយៈព្រះពុទ្ធសាសនា គឺវិធីបង្រួបបង្រួមផ្សះផ្សាជាតិ ។

ចាប់តាំងពីខ្មែរបានលើកលែងទោស ឈប់ប្រហារគ្នាទៅវិញទៅមក ដោយគ្រឿងសាស្ត្រាវុធបាន ប្រកាន់ខ្ជាប់យកនូវព្រះធម៌ជាធំ ខ្មែរក៏បានទទួលនូវសុខសន្តិភាពជានិរន្តរ៍តរៀងមក រហូតដល់សម័យបច្ចុប្បន្ននេះ។ ខ្មែរបានកាន់យកនូវព្រះពុទ្ធសាសនា តាំងពីសម័យនគរភ្នំ គឺចាប់តាំងពីសតវត្សទី១នៃគ.ស (និកាយហិនយាន) ហើយបានរីកចម្រើននៅក្នុងសតវត្សទី២ នៃគ.ស រហូតដល់សព្វថ្ងៃនេះ ក្នុងច្បាប់រដ្ឋធម្មនុញ្ញរបស់ខ្មែរគ្រប់ជំនាន់ បានកំណត់ទុកថា "ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ" ហើយថែមទាំងបានបង្កើតក្រសួងមួយ ឈ្មោះក្រសួងធម្មការនិងសាសនា សម្រាប់គ្រប់គ្រងស្ថាប័នសាសនា ជាពិសេសគឺសាសនារបស់ព្រះពុទ្ធហ្នឹងឯង។

## ធុរៈក្នុងព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា មានធុរៈពីរគឺ គន្ថធុរៈ១ វិបស្សនាធុរៈ១ ។

**-គន្ថធុរៈ** : ជាធុរៈមួយផ្នែកខាងសិក្សាសូត្ររៀននូវព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ។

**-វិបស្សនាធុរៈ** ជាធុរៈផ្នែកខាងអប់រំទូន្មានចិត្ត ។

## សកម្មភាពព្រះពុទ្ធសាសនាខ្មែរនាបច្ចុប្បន្ន

ចាប់តាំងពីខ្មែរបានទទួលព្រះពុទ្ធសាសនាមក ធុរៈទាំងពីរគឺ គន្ថធុរៈ១ វិបស្សនាធុរៈ១ ប្រជាពលរដ្ឋខ្មែរ បានទ្រទ្រង់រៀងរាបដរាប មកដល់សម័យបច្ចុប្បន្ននេះ ។

**-គន្ថធុរៈ** ខ្មែរបានរៀបចំឱ្យមានការសិក្សារៀនសូត្រ រហូតដល់បានបង្កើតពុទ្ធិកសិក្សាថ្នាក់បឋម ភូមិ មធ្យមភូមិ និង ឧត្តមភូមិ ព្រមទាំងសាលាធម្មវិន័យថ្នាក់ត្រី ទោ ឯកផងដែរ។

**-វិបស្សនាធុរៈ** : វិបស្សនាធុរៈ ជាកិច្ចការដ៏សំខាន់មួយសម្រាប់អប់រំផ្លូវចិត្ត កាលពីសម័យខាង ដើមរហូតមកដល់ឆ្នាំ១៩៨៦ ប្រជាពលរដ្ឋខ្មែរតែងមានការគោរពប្រតិបត្តិព្រះធម៌តាមផ្លូវវិបស្សនាធុរៈនៅ តាមវត្ត ឬ អាស្រម ឬ តំបន់មានភ្នំ ឬ ព្រៃជាដើម ជាហូរហែមក ក៏ប៉ុន្តែមិនទាន់មានរចនាសម្ព័ន្ធគ្រប់គ្រងជាអង្គការច្បាប់នៅឡើយ ។ ការប្រតិបត្តិនោះដោយឡែក១ពីគ្នា ប្រព្រឹត្តទៅ

តាមចំណេះចេះដឹងរបស់ គ្រូវិបស្សនានីមួយៗ លុះមកដល់មុនឆ្នាំ១៩៩៦ នៅប្រទេសកម្ពុជាមានពុទ្ធបរិស័ទជាច្រើនចូលចិត្តគោរព ប្រតិបត្តិព្រះធម៌ តាមផ្លូវវិបស្សនា។ ព្រះពុទ្ធសាសនាផ្នែកខាងវិបស្សនាធុរៈនេះ តែងមានការអភិវឌ្ឍន៍ច្រើន ទៅបន្តិចម្តងៗ ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ឆ្នាំ១៩៩៦ សម្តេចព្រះសង្ឃរាជគណៈមហានិកាយព្រះនាម **ទេព វង្ស** ទ្រង់បានសម្រេចព្រះហឫទ័យបង្កើតឡើងនូវ ប្រព័ន្ធសិក្សាថ្មីមួយ ដែលប្រទេសកម្ពុជាមិនធ្លាប់មានពីមុនមក ហៅថា "ប្រព័ន្ធសិក្សាព្រះពុទ្ធសាសនាផ្នែកខាងវិបស្សនាធុរៈ"។ ដើម្បីរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងផ្នែកវិបស្សនាធុរៈឱ្យមានការសិក្សាឯកភាពគ្នាតាម គម្ពីរវិសុទ្ធិមគ្គ ឬ គម្ពីរព្រះត្រៃបិដក សម្តេចព្រះសង្ឃរាជក៏បានបង្កើតមជ្ឈមណ្ឌលវិបស្សនាធុរៈមួយ ដែលមានទីស្នាក់ការបណ្តោះអាសន្ននៅវត្ត **នន្ទមុនី** សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញហើយបានបង្កើតនូវគណៈកម្មាធិការមួយក្រុមដែលមានព្រះធម្មវិបស្សនា **សំ ប៊ុនធឿន** កេតុធម្មោ ជាប្រធាន សម្រាប់ឱ្យមជ្ឈមណ្ឌលវិបស្សនាធុរៈនោះមានដំណើរការ។ វិបស្សនាធុរៈដែលបានរៀបចំឱ្យ កើតមានឡើង ដោយមានប្រព័ន្ធគ្រប់គ្រងតាមបែបរដ្ឋបាល មានការសិក្សាបែងចែកជាបីថ្នាក់គឺ ៖

-បឋមវិបស្សនា សិក្សារយៈពេល០៣ឆ្នាំ

-មធ្យមវិបស្សនា សិក្សារយៈពេល០៤ឆ្នាំ

-ឧត្តមវិបស្សនា សិក្សារយៈពេល០៥ឆ្នាំ

ចាប់តាំងពីឆ្នាំ១៩៩៦ រហូតដល់សព្វថ្ងៃនេះ មានពុទ្ធសាសនិកចំនួនរាប់ពាន់នាក់ នៅតាមបណ្តា ខេត្ត-ក្រុង ដែលបានទទួលការអប់រំចិត្តតាមផ្លូវវិបស្សនាធុរៈ(ចម្រើនសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន)។ កាលបើផ្លូវប្រតិបត្តិវិបស្សនាធុរៈចេះតែមានការរីកចម្រើនជាលំដាប់ មជ្ឈមណ្ឌលវិបស្សនាធុរៈ (កន្លែងប្រមូលផ្តុំប្រតិបត្តិធម៌តាមផ្លូវវិបស្សនា) ក៏បានក្លាយទៅជាពុទ្ធមណ្ឌលវិបស្សនាធុរៈសព្វថ្ងៃមាន ទីតាំងស្ថិតនៅទិសខាងលិចភ្នំអដ្ឋរស្ស ក្នុងឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ហើយមានមជ្ឈមណ្ឌល វិបស្សនាធុរៈខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងមណ្ឌលវិបស្សនាធុរៈតាមវត្តជាច្រើន ជាសាខារបស់ខ្លួន ។

## និបស្សនាធុរៈ

វិបស្សនាធុរៈ ជាកិច្ចប្រតិបត្តិមួយដ៏សំខាន់ក្នុងការអប់រំចិត្ត ។ ចិត្តជានាមធម៌ ជាធម្មជាតិប្លែងប្លោង ឆាប់កម្រើកញាប់ញ័រនៅពេល ដែលប៉ះទង្គិចនិងអារម្មណ៍ ពិបាករក្សាផ្ចុញផ្ចាល់បានដោយកម្រ កើតរលត់រហ័ស ប្រព្រឹត្តទៅតាមទ្វារ៦មានទ្វារភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងមនោទ្វារ ។ ចិត្តនេះកាលបើមិនទាន់បានអប់រំតែងលិចចុះទៅក្នុងអំណាច នៃ តណ្ហា(សេចក្តីប្រាថ្នា) ។

កាលបើតណ្ហាគ្របសង្កត់ហើយ ចិត្តតែងស្វែងរកអារម្មណ៍ ហើយប្រមូលទុកក្នុងខ្លួនយ៉ាងច្រើន ។

ក្នុងពេលចិត្តស្វែងរកអារម្មណ៍នោះ ជួនកាលក៏ប្រទះនឹងអារម្មណ៍ល្អ ជួនកាលក៏ប្រទះនឹងអារម្មណ៍ អាក្រក់ជាទីគាប់ចិត្តខ្លះ មិនជាទីគាប់ចិត្តខ្លះ ។ ម្ល៉ោះហើយ សេចក្តីសោក ខ្សឹក ខ្សួល ទុក្ខទោមនស្ស ឬ ភាពរីករាយ ស្រស់ស្រាយក៏កើតឡើងក្នុងចិត្តរឿយៗ ។ កាលបើចិត្តមានភាពប្រែប្រួល ទៅតាមខ្សែនៃអារម្មណ៍ដូច្នេះហើយ សត្វលោកទាំងអស់តែងទទួលរងនូវសេចក្តីទុក្ខគ្រប់យ៉ាង ។

នៅក្នុងលោកនេះ ធម៌សម្រាប់រំដោះខ្លួនឱ្យចេញផុតចាកសេចក្តីទុក្ខ គ្មានធម៌អ្វីក្រៅពីវិបស្សនាធុរៈឡើយ ។

**គុណធម៌ដែលកើតឡើងក្នុងវិបស្សនាធុរៈ**

ក្នុងសម័យដែលពុទ្ធបរិស័ទឃើញភ័យក្នុងវដ្តៈ ជាអ្នកស្អប់ទុក្ខស្រឡាញ់សុខ ហើយបានបង្អោនចិត្តចូលទៅប្រតិបត្តិក្នុងកម្មដ្ឋាន សម័យនោះការ សង្រួមកាយចិត្តក៏នឹងកើតឡើង ។ កាលបើការសង្រួម កាយចិត្តមានហើយ សីលសំវរៈ (សេចក្តីសង្រួមក្នុងសីល) ក៏នឹងកើតឡើង កាលបើសីលមានហើយ សមាធិចិត្ត (ចិត្តនឹងមូលក្នុងអារម្មណ៍តែមួយ) ក៏នឹងកើតឡើង កាលបើសមាធិមានហើយ បញ្ញាដែលឃើញ ច្បាស់នូវកងសង្ខារកើតរលត់ក្តី សេចក្តីនឿយណាយ

ប្រាសចាកតម្រេក អស់សេចក្តីប្រាថ្នា និងភាពមិនជាប់ ជំពាក់ក្នុងសង្ខារធមិ ក៏នឹងកើតឡើងតាមលំដាប់ ។

ត្រង់ចំណុចដែលមិនជាប់ជំពាក់ក្នុងសង្ខារធមិនោះឯង ជាគុណធមិដ៏ពិសេស ។ មនុស្សសត្វទាំង អស់ក្នុងលោកដែលមានជីវិតរស់នៅ មិនមានសេចក្តីហួងហែងប្រកាន់ខ្លួន. ប្រកាន់វណ្ណៈ ពូជសាសន៍ ជាតិត្រកូលឈ្មោះថា មនុស្សនោះ ជាអ្នករស់នៅស្គាល់ប្រមាណខ្លួន ហើយចេះសម្របសម្រួលរស់នៅស្របតាមសង្គម ។ ប្រសិនបើមនុស្សនៅក្នុងសកលលោក បានអប់រំចិត្តដូច១គ្នា ពិភពលោកទាំងមូលប្រាកដជា នឹងបានសុខសន្តិភាពជានិរន្តរ៍តរៀងទៅ ។

តាមស្ថានភាព

និងបទពិសោធន៍របស់ពុទ្ធមណ្ឌលវិបស្សនាធុរៈនៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងប្រព្រឹត្តទៅក្នុងសម័យបច្ចុប្បន្ន អំពីបញ្ហាវិបស្សនា និងសង្គមមនុស្សទូទៅ បានបញ្ជាក់ឱ្យឃើញថា :

វិបស្សនាបានជួយស្តារឡើងវិញនូវសីលធមិក្នុងសង្គម បានជួយអប់រំចិត្តរបស់មនុស្សដែលកំពុង មានសេចក្តីទុក្ខគ្របសង្កត់ ជាពិសេសបាន ជួយនូវឋាមពលក្នុងការកសាងសន្តិភាពក្នុងសង្គមជាតិទូទៅ ។

## ទិបស្សនាធុរៈ និងស្ត្រីខ្មែរ

នៅក្នុងបច្ចុប្បន្នលោក មនុស្សរស់នៅក្នុងសង្គមមានភេទពីរគឺ បុរស១ ស្ត្រី១ តាមច្បាប់ធម្មជាតិ កាលបើបុរស-ស្ត្រីមានវ័យចម្រើនធំឡើងតែង បាន គ្នាជាប្តី-ប្រពន្ធ ជាធម្មតា។ មនុស្សទាំងអស់ដែលគ្មាន ប្រាជ្ញាតែងរស់នៅ លុះក្នុង អំណាចនៃតណ្ហា(សេចក្តីប្រាថ្នា) គ្រប់ពេលវេលា ម្ល៉ោះហើយសេចក្តីត្រូវការរបស់ មនុស្សរកទីបំផុតគ្មាន។ ព្រះពុទ្ធអង្គទ្រង់ពោលថា "ទឹកសមុទ្រមានជោរ មាននាច រីឯតណ្ហារបស់សត្វ លោកគ្មានចេះនាចសោះឡើយ" ។

តណ្ហានេះ បើមនុស្សមិនចេះបង្អន់ទេ មុខជានឹងរីកធំទូលាយរក ទីបំផុតគ្មាន ព្រះពុទ្ធទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តណ្ហានេះបើមានរូបរាង ជាគ្រឿងកត់សម្គាល់គឺរកទីសម្រាប់ដាក់តណ្ហានោះមិនបានឡើយ ឋានមនុស្ស រហូតដល់ឋានព្រហ្ម ទីទំហំប្រមាណប៉ុណ្ណេះចង្អៀតពេកណាស់។

ស្ត្រីខ្មែរមួយចំនួនមានទឹកភ្នែកជោគមុខ ព្រោះតែតណ្ហារបស់ប្តីគ្មាន កម្រិត បានភរិយាមួយហើយ ពុំចេះស្កប់ចិត្តស្វែងរកស្ត្រីដទៃទៀត មកធ្វើជា ប្រពន្ធ ម្ល៉ោះហើយក្នុងគ្រួសារនោះគ្មានការព្រមព្រៀងគ្នាល្អឡើយ តែងមាន ទំនាស់ ទាស់ទែងឈ្លោះប្រកែកគ្នាជាធម្មតា។ នៅពេលដែលប្តីមានប្រពន្ធថ្មីទៀត ស្ត្រីដែលជាប្រពន្ធដើមតែងកើតទុក្ខរឿយៗ រហូតដល់ស្ត្រីខ្លះសម្លាប់ខ្លួនឯងក៏មាន ឬក៏ឈឺរីងរៃរកកលស្ទើរមរណា ស្ត្រីខ្លះមានប្រាជ្ញាស្វែងរកធម៌អាថ៌ដើម្បីជួយដោះ

ស្រាយបញ្ហាជីវិត។ ស្ត្រីនោះក៏បានរំដោះខ្លួនចេញចាកសេចក្តីទុក្ខ ដោយការពិចារណាឃើញព្រះធម៌ ឃើញច្បាស់តាមសេចក្តីពិត។

## វិបស្សនា និងសង្គមខ្មែរ :

វិបស្សនាធុរៈ ជាកិច្ចប្រតិបត្តិមួយដ៏សំខាន់ក្នុងការព្យាបាលនូវរោគផ្លូវចិត្ត និងកំចាត់បង់នូវកម្មពៀរវេរា ដែលជាប់ពីអតីតជាតិ ឬ ក្នុងជាតិនេះ ដែលបុគ្គលបានធ្វើហើយក្នុងកាលមុន។ ថ្មី១នេះមានគ្រួសារមួយមានគ្នាចំនួន៤នាក់គឺ ប្តីប្រពន្ធ កូន និងម្តាយ ដែលមានសញ្ជាតិខ្មែរអូស្ត្រាលី បានកើតរោគភ័យខ្លាចដែលកើតអំពីវិបាកនៃកម្មចាស់។ រោគាព្យាធិនេះ បានធ្វើឱ្យក្រុមគ្រួសារដូចបានពោលហើយខាងលើ រន្ធត់ញាប់ញ័រ តក់ស្លុត រហូតដល់រស់នៅផ្ទះពុំបាន។ មានសម័យមួយគួរឱ្យអាណោចអាធម្មយ៉ាងក្រៃពេក ក្រុមគ្រួសារនេះកាលបើរោគភ័យខ្លាចកើតឡើង ក៏បានលះបង់ផ្ទះសម្បែង ធ្វើដំណើរទៅសុំផ្ទះជនដទៃជ្រកកោន ជនទាំងឡាយនោះ គេមិនឱ្យចូលផ្ទះរបស់គេទេ ព្រោះគេខ្លាចកើតរោគដូចគ្រួសារនោះ។ ជនទាំង៤នាក់ ក៏ចាប់ផ្តើមធ្វើដំណើរផ្សងព្រេងចេញចាកប្រទេសអូស្ត្រាលី ទៅកាន់ប្រទេសដទៃ ដើម្បីរកគ្រូព្យាបាលរោគរបស់ខ្លួន គ្រូពេទ្យទាំងឡាយ ទាំងផ្លូវលោក ទាំងផ្លូវធម៌ ទោះជាខំប្រឹងប្រែងព្យាបាលរោគក្រុមគ្រួសារនោះដោយវិធីសាស្ត្រផ្សេង១ យ៉ាងណាក៏ដោយ ក៏ក្រុមគ្រួសារនោះ

នៅតែមិនបានជាសះស្បើយឡើយ គ្រាន់តែធូរស្រាលបន្តិចបន្តួចប៉ុណ្ណោះ ។ សម័យថ្ងៃមួយ ពួកគេក៏បានធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ដើម្បីជួបជុំញាតិមិត្ត ដែលត្រូវជាបងប្អូនរបស់ខ្លួន ដើម្បីឱ្យគេជួយព្យាបាលរោគ ក៏ប៉ុន្តែ ក្រុមញាតិទាំងអស់នោះ គ្មានសមត្ថភាពជួយគ្រួសារនោះឡើយ ។ វាសនាល្អ នាសម័យជិតឡើងយន្តហោះវិលត្រឡប់ទៅកាន់ប្រទេសអូស្ត្រាលីវិញ ស្រាប់តែឧបនិស្ស័យល្អដែលក្រុមគ្រួសារនោះបានសន្សំទុកហើយក្នុងអតីតកាល បានញ៉ាំងចិត្តរបស់ពួកគេឱ្យនឹកឃើញដល់ពុទ្ធមណ្ឌលវិបស្សនាធុរៈភ្នំអដ្ឋវង្ស ឱ្យគិតឃើញថាមុននឹងពួកយើងធ្វើដំណើរទៅកាន់ស្រុកវិញ ជាការល្អ គួរតែទៅថ្វាយបង្គំ នមស្ការចំពោះព្រះថេរៈ **សំ ប៊ុនធឿន** ដែលជាគ្រូវិបស្សនាធុរៈមួយរូបក្នុងប្រទេសកម្ពុជាជាមុនសិន។ ពេលជួបព្រះថេរៈអង្គ នោះហើយៗក៏បានសាកសួរនូវថ្នាំសម្រាប់ព្យាបាលរោគរបស់ខ្លួន។ ក្នុងពេលនោះ ព្រះអង្គទ្រង់មានព្រះថេរៈដីកាថា : រោគរបស់អ្នករាល់គ្នា បើចង់ជា លុះត្រាតែចម្រើនកម្មដ្ឋាន ជនទាំងអស់នេះកាលបើបានឮថេរៈដីកាដូច្នោះហើយ ក៏បានពន្យាពេលក្នុងការធ្វើដំណើរទៅកាន់ប្រទេសអូស្ត្រាលី ហើយក៏បានចូលមកសិក្សាវិបស្សនាធុរៈមួយរយៈពេលខ្លីប្រមាណជាង១០ថ្ងៃប៉ុណ្ណោះ ក្រុមគ្រួសារនោះ ក៏បានស្ងប់រម្ងាប់នូវរោគាព្យាធិទាំងអស់ក្នុងរូបកាយ គឺសេចក្តីភ័យខ្លាច រន្ធត់ញាប់ញ័រក៏វិនាសអស់ពីក្នុងសន្តានចិត្ត។ ជាពិសេស បុរសជាប្តី បានយល់ច្បាស់នូវព្រះធម៌ជាងគេរហូត

ដល់មានចិត្តតាំងនៅមាំ មានសតិស្មារតីប្រាជ្ញាមោះមុត អាចរក្សាខ្លួន រក្សាក្រុមគ្រួសារ និង អាចញាំងជនដទៃឱ្យប្រតិបត្តិចំពោះកម្មដ្ឋានដូចជាខ្លួនដែរ ។ លើករឿងនេះមកដើម្បីជាសក្ខីភាពមួយដែលថា ព្រះអានាបានស្សតិកម្មដ្ឋាន កាលបើបុគ្គលបានចម្រើនទៅហើយ នឹងបានទទួលលទ្ធផល គឺបានជារោគផ្លូវកាយផង ផ្លូវចិត្តផង ហើយថែមទាំងបានបុណ្យកុសលនិរន្តរ៍តទៅ គ្រប់ពេលវេលា។ ដូច្នេះ ការបតិបត្តិនូវព្រះធម៌នេះ គឺមានប្រយោជន៍ ហើយបានបុណ្យធ្វើឱ្យជីវិតរបស់មនុស្សសត្វភ្លឺស្វាង ធ្វើឱ្យបុគ្គលអ្នកចម្រើនបានសេចក្តីសុខសាន្តអាយុវែង និងបន្ទាប់អំពីស្លាប់ទៅ នឹងបានទៅកើតក្នុងសុគតិ បើមិនទាន់ដល់ព្រះនិព្វាន។ ដូច្នេះសូមពុទ្ធបរិស័ទ សាធុជនទាំងអស់ ដែលមានជីវិតរស់នៅមិនត្រូវមានសេចក្តីប្រមាទឡើយ ត្រូវខំប្រឹងរៀនសូត្រនូវធម៌អាថ៌ ដើម្បីរំដោះខ្លួនឱ្យចេញផុតពីសេចក្តីទុក្ខគ្រប់ៗគ្នាឡើង កុំធ្វេសប្រហែសឱ្យសោះ ត្រូវមានសេចក្តីព្យាយាមជានិច្ចក្នុងការរស់នៅរបស់ខ្លួនម្នាក់ៗ គឺរស់នៅក្រោមឱវាទព្រះសម្មាសម្ពុទ្ធជាម្ចាស់របស់សត្វលោកទូទៅ ។ សេចក្តីដែលបានពោលរួចមកហើយ បញ្ជាក់ឱ្យឃើញថា វិបស្សនាធុរៈទុកដូចជាឱសថដ៏ពិសេសមួយ ក្នុងចំណោមឱសថទាំងឡាយក្នុងលោក ។

ឱសថក្រុមគ្រូពេទ្យទាំងឡាយបានស្គួ ចម្រាញ់ហើយ ក៏ជាឱសថដ៏ពិសេសមួយដែរ សម្រាប់ព្យាបាលរោគតាមផ្លូវកាយ តែមិនអាចព្យាបាលរោគ

តាមផ្លូវចិត្តបានឡើយ ។ ចំណែកឱសថគឺវិបស្សនាធម៌ ជាឱសថសម្រាប់ជួយព្យាបាលរោគតាមផ្លូវចិត្តដោយពិត ។ ហេតុដូច្នោះ សាធុជនទាំងប្រុស-ស្រី កាលបើមានរោគាព្យាធិកើតឡើងក្នុងករជកាយ គួរតែស្វែងរកថ្នាំដែលកើតពីដើមឈើជាដើម យកមកព្យាបាលរោគ តែប្រសិនបើជម្ងឺផ្លូវចិត្តដែលកើតឡើងពីកម្មវិបាក( ផលនៃកម្ម) ឬ សម្ពាធនៃអាកាសធាតុ ឬក៏សម្ពាធនៃសង្គមជាដើម គួរស្វែងរកព្រះធម៌ជាទីពឹង ចម្រើនកម្មដ្ឋានសម្អាតចិត្តឱ្យបរិសុទ្ធ រម្ងាប់នូវរោគ សោយនូវ បីតិ និងសុខៈ ដើម្បីរស់នៅក្នុងបច្ចុប្បន្ន ។

វិបស្សនាធុរៈមិនមែនត្រឹមតែជួយមនុស្សឱ្យជារោគតាមផ្លូវចិត្ត និង កាយប៉ុណ្ណោះទេ ថែមទាំងជួយសម្រុះសម្រួលដល់សង្គមមនុស្សឱ្យចេះរស់ នៅជាមួយគ្នា ដោយគ្មានទំនាស់ ។ ហេតុអ្វី ? ព្រោះថា ធម៌វិបស្សនានេះ កាលបើមនុស្សក្នុងសង្គម អប់រំចម្រើនឱ្យច្រើនហើយ មនុស្សក្នុងសង្គម ក៏នឹងអាចឃើញនូវសេចក្ដីពិតបាន ឃើញថាអត្តភាពនៃបុគ្គលម្នាក់ៗគ្មានសារៈសំខាន់អ្វីឡើយ មានត្រឹមខន្ធ៥ អាយតនៈ១២ ធាតុ១៨ ឬ ធាតុ៤ គឺទឹក ដី ភ្លើង ខ្យល់ ប្រជុំគាក់តែងក្នុងទីជាមួយគ្នា ឬ ឃើញត្រឹមតែសង្ខារធម៌មានកិរិយាកើតឡើង វិនាសទៅវិញជាធម្មតា មិនឃើញមានសត្វបុគ្គលស្រី-ប្រុស ចិន ចាម ជ្វា ខ្មែរ ថៃ លាវ វៀតណាមឡើយ ។ កាលបើមនុស្សក្នុងសង្គមបានឃើញនូវសភាវៈ ពិតដូចបានពោលហើយយ៉ាងនេះ ក៏នាំគ្នាឈប់ប្រកាន់គ្នានឹងគ្នា ហើយក៏ចែកគ្នារស់ដោយ

ស្រួលទៅវិញទៅមក ។ វិបស្សនាធុរៈ អាចជួយមនុស្សរលត់ស្មារតី ឱ្យមានស្មារតីបាន ក្នុងសម័យពុទ្ធកាលមានរឿងនាងបដាចារាឬនាងកិសាគោតមីជាដើម ដល់ពេល ចូលកាន់មរណភាព រមែងស្លាប់ស្រួលមិនលំបាកហើយនិងបានទៅកើតក្នុងសុគតិសួគ៌ ។ ម្យ៉ាងទៀត វិបស្សនាមិនត្រឹមតែជួយមនុស្សឱ្យបានសុខក្នុងសំសារវដ្តប៉ុណ្ណោះទេ ថែមទាំងជួយមនុស្សឱ្យផុតចាកសេចក្តីទុក្ខ ហើយបានសម្រេចនូវព្រះនិព្វានទៀតផង ។ ដូច្នេះ សាធុជនទាំងឡាយ រស់នៅក្នុងជីវិតប្រចាំថ្ងៃ គួរប្រកបអាជីវកម្ម ហើយចម្រើនវិបស្សនាផង ។ ព្រះធម៌នាំឱ្យមានការរស់នៅស្រួលក្នុងលោកនេះ និងក្នុងលោកខាងមុខផង រហូតមកដល់ស្ថានព្រះនិព្វានពោង ។

### សន្និដ្ឋាន

ព្រះពុទ្ធសាសនាជាសាសនាមួយ ប្រៀនប្រដៅសត្វលោក ឱ្យជឿទៅលើកម្មនិងផល ឱ្យជឿទៅលើខ្លួនឯងជាអ្នកសម្រេចនូវជោគវាសនារបស់ខ្លួន ជាពាក្យប្រៀនប្រដៅមានលក្ខណៈវិទ្យាសាស្ត្រ មានកត្តាកំណត់ត្រឹមត្រូវច្បាស់លាស់ ។ ប្រសិនណា បើមនុស្សទាំងអស់មានជំនឿថា អាក្រក់ ឬ ល្អ សុខ ឬ ទុក្ខ ។ល។ គឺខ្លួនជាអ្នកសាងមនុស្សទាំងអស់នឹងសាងតែអំពើល្អតែម្យ៉ាង ។ កាលបើមនុស្សក្នុងសកលលោក កសាងតែអំពើល្អគ្រប់ៗរូប ពិភពលោកនឹងបានសុខសន្តិភាពជានិរន្តរ៍តរៀងទៅ ។

## មនុស្សស្លាប់កើតទៀតឬទេ ?

៤៦*៤៩

**សេចក្តីផ្តើម** :

ទស្សនៈស្លាប់និងកើត របស់សត្វទាំងឡាយនៅក្នុងលោកនេះ មានច្រើនបែបច្រើនយ៉ាង ។ គណាចារ្យ ពួកខ្លះបានយល់ឃើញថា សត្វដែលស្លាប់ហើយទៀងតែនឹងកើតទៀត ហើយមានសភាពទៀងទាត់ដោយកំណើត ទៀតផង ខ្លះទៀតយល់ឃើញថា សត្វស្លាប់ទៅសូន្យមិនកើតទៀតក៏មាន។ មានគណាចារ្យដទៃទៀត ខ្លះបានយល់ឃើញផ្សេងពីនេះថា សត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន កើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មាន កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក៏មាន ។

តើទស្សនៈរបស់ព្រះពុទ្ធសាសនា ដែលពោលអំពីសត្វស្លាប់កើតទៀតយ៉ាងណា ?

ដើម្បីដោះស្រាយពីបញ្ហាខាងលើនេះ ខ្ញុំសូមលើកយកមាតិកានៃធម៌ដែលទាក់ទងពីកំណើតនិងសេចក្តី ស្លាប់នោះមកតាងទុកដើម្បីបកស្រាយដូចតទៅ :

-សត្វគឺជាអ្វី ?

-ភពបី

-កំណើតបួន

-ត្រូវកំណើត

-ហេតុនាំឱ្យកើត

-ភស្តុតាងនៃកំណើត

-និញ្វនធាតុ

## សត្វជាអ្វី ?

ពាក្យថា សត្វ ដែលយើងពោលសព្វថ្ងៃបើនិងភាវៈកកំណើតដើម បាន ឱ្យឃើញថា ពាក្យថាសត្វនេះជា ខេមរភាសាដែលកម្លាយចេញមកពីភាសាសំស្ក្រឹតថា សត្វ អានថា "សាត់ត្វាក់" ឯភាសាបាលីថា សត្ត អានថា "សាត់តាក់" ។ បើពោលដោយអត្ថន័យមានន័យថា ជនណាដែលជាប់ក្នុងបំណង ឬ ជាប់ជំពាក់ក្នុងអារម្មណ៍លោក ហៅជននោះថា ជាសត្វ ។

## ភពគឺ

ភព គឺជាទីកន្លែងដែលពពួកសត្វយកកំណើត រស់នៅ និងស្លាប់ មានបីយ៉ាងគឺ : កាមភព១ រូបភព១ អរូបភព១ ។

### ១-កាមភព :

ជាភពមួយដែលពពួកសត្វរស់នៅអាស្រ័យនឹងកាមគុណ (មានប្តី-ប្រពន្ធ) បើចែកមាន១១ជាន់គឺ អបាយ ភូមិ៤. មនុស្ស១. ទេវតា៦ជាន់ ។

អបាយភូមិ៤ នោះគឺ នរក១. ប្រេត១. អសុរកាយ១ និង តិរច្ឆាន១ ។

-នរក គឺជាពពួកសត្វដែលរស់នៅដោយសេចក្តីឈឺចាប់ ដូចមានភ្លើងឆេះជាប្រក្រតីជាដើម ។

-ប្រេត គឺជាពពួកសត្វដែលរស់នៅដោយទុក្ខវេទនា មានការស្រេកឃ្លានជាប្រក្រតីជាដើម ។

-អសុរកាយ គឺជាពពួកសត្វមានកាយមិនប្រាកដ ជួនមើលឃើញ ជួនមើលមិនឃើញ ។ ពពួកសត្វនេះ ខ្លះក៏រស់នៅប្រកបដោយសេចក្តីទុក្ខ ខ្លះក៏រស់នៅប្រកបដោយសេចក្តីសុខ ។

-តិរច្ឆាន គឺជាពពួកសត្វមានខ្លួនដើរទៅទទឹងថ្ងៃ គ្មានជើងខ្លះ មានជើង២ខ្លះ ៤ខ្លះ និងជើងច្រើនខ្លះ ។ ពពួកសត្វនេះរស់នៅគ្មានសេចក្តីចម្រើនទេ ជាសត្វគ្មានប្រាជ្ញា មានត្រឹមតែភាវគតិ រស់នៅតាមកម្រិតនៃធម្មជាតិ គាត់តែងឱ្យ ។ តួយ៉ាងដូចសត្វគោរស់នៅដោយមានស្មៅជាអាហារជាដើម ។

មនុស្ស ជនណាដឹងនូវល្អ និងហេតុអាក្រក់ ហៅថាមនុស្ស ។

ទេវតា៦ជាន់ គឺចាតុម្មហារាជិកា១. តាវត្តិង្សា១. យាមា១. តុសិតា១. និម្មានរតី១. បរនិម្មិតវសវត្តី១ ។

២-រូបភព :

បានដល់ភពព្រហ្មមានរូប សត្វពួកនេះកើតឡើងរស់នៅក្នុងភព មិនបរិភោគកាមគុណ ជាសត្វគ្មានភេទស្រីឬប្រុសឡើយ រស់នៅអាស្រ័យនឹងឈានដែលខ្លួនតាក់តែងឱ្យកើតឡើងហើយក្នុងកាលមុន ។

ព្រហ្មនោះមាន១៦ជាន់គឺបារិសជ្ជា១. បរោហិតា១. អប្បមាណសុភា១. សុភកិណ្ហា១. វេហប្ផលា១. អសញ្ញីសត្តា១. អវេហា១. អតប្បា១. សុទស្សា១. សុទស្សី១. អកនិដ្ឋា១ ។

៣-អរូបភព :

បានដល់ភពព្រហ្មគ្មានរូប មាន៤ជាន់គឺ អាកាសានញ្ចាយតនៈ១. វិញ្ញាណញ្ចាយតនៈ១. អកិញ្ចញ្ញា-យតនៈ១. នេវសញ្ញានាសញ្ញាយតនៈ១។ ពួកព្រហ្មគ្មានរូបនេះការកើតឡើងមានត្រឹមតែអរូបក្ខន្ធ១រស់នៅក្នុងភពប៉ុណ្ណោះ អាស្រ័យនៅបានដោយឈានដែលខ្លួនតាក់តែងឱ្យកើតហើយក្នុងកាលមុន ។

**កំណើត៤**

ពួកសត្វក្នុងលោកទាំងបី បើបែងចែកកំណើតមាន៤គឺ :

១-អណ្ឌជកំណើត កើតពីស៊ុតដូចមាន់. ទា. ក្ងាន. ចាប ជាដើម ។

២-ជលាពុជកំណើត កើតពីពូជ គឺទឹកកាមដែលសត្វញី ឬ ឈ្មោល ប្រុស និងស្រី បានជួបប្រសព្វសេពសន្ធវៈជាមួយគ្នាដោយតម្រេក ញ៉ាំងកូនឱ្យ

LIBRARY BUDDHIST INST

កើតឡើងដូចសត្វគោ,ក្របី,ឆ្កែ,ឆ្មា. មនុស្សជាដើម( កូនអាស្រ័យក្នុង ផ្ទៃដល់កំណត់ខែហើយ ទើបប្រសូត្រចេញមកខាងក្រៅ) ។

៣-សំសេទជកំណើត កើតពីញើសក្អែល ដូចសង្កើច, ដង្កូវទឹក, មមាច, មមុង ជាដើម ។

៤-ឧបបាតិកកំណើត ឧប្បត្តិកកើតឡើងធំភ្លាម១ ដោយអំណាចនៃបាប និងបុណ្យ មាននរក, ប្រេត, អសុរកាយ, យក្ស, គន្ធព្វ, ទេវតា, ព្រហ្ម ជាដើម ។

## តួកំណើត

តើពពួកសត្វក្នុងលោកទាំងអស់មានអ្វីជាតួកំណើត ?

ចិត្តមានចំនួន១៩ លោកហៅថា ទ្វារវិមុត្តកៈ ជាអ្នកដើរតួឯកក្នុងកិរិយាតភ្ជាប់នូវកំណើតថ្មីក្នុងភព សំសារនៃយើងនេះ ។ ហើយចិត្តទាំង១៩ នោះ សុទ្ធតែជាតួផលនៃកម្មទាំងអស់ដូច១គ្នា ។

ចិត្តនោះគឺ អកុសលវិបាកអហេតុកចិត្ត១, កុសលវិបាកអហេតុកចិត្ត១, កាមាវចរកុសលវិបាក៨, រូបាវចរកុសលវិបាក៥, អរូបាវចរកុសលវិបាក៤ ។

-កុសលាកុសលវិបាកអហេតុក២នោះគឺ :

ឧបេក្ខាសហគតសន្តីរណៈ ចិត្តដែលពិចារណានូវអារម្មណ៍ប្រកបដោយឧបេក្ខាវេទនា ដែលជាតួអកុសល វិបាកអហេតុចិត្តទី៧ ជាតួបដិសន្ធិ (យកកំណើត)របស់សត្វក្នុងអបាយភូមិ៤ ។

ឧបេក្ខាសហគតសន្តីរណចិត្ត ចិត្តពិចារណានូវអារម្មណ៍ប្រកបដោយឧបេក្ខាវេទនា ដែលជាកុសលវិបាក អហេតុចិត្តទី៨ ជាតួបដិសន្ធិរបស់សត្វមានបុណ្យតិច ។

កាមាវចរកុសលវិបាក( មហាវិបាក )៨ ជាតួបដិសន្ធិរបស់មនុស្សដែលមានបុណ្យច្រើន និងទេវតា៦ ជាន់ ។

**-កាមាវចរកុសលវិបាក៨នោះគឺ :**

១-សោមនស្សសហគត ញាណសម្បយុត្ត អសង្ខារិក វិបាកចិត្តប្រកបដោយសោមនស្សវេទនា និងព្រមដោយប្រាជ្ញា មិនប្រកបដោយសង្ខារ គឺមិនមានបុគ្គលមកដឹកនាំ( ក្លៀវក្លាដោយទំនើងខ្លួនឯង) ។

២-សោមនស្សសហគត ញាណសម្បយុត្ត សសង្ខារិក វិបាកចិត្តប្រកបដោយសោមនស្សវេទនានិងព្រមដោយប្រាជ្ញា ប្រកបដោយសង្ខារគឺ មានបុគ្គលមកដឹកនាំ( មិនក្លៀវក្លាដោយទំនើងខ្លួនឯង) ។

៣-សោមនស្សសហគត ញាណវិប្បយុត្ត អសង្ខារិក វិបាកចិត្តប្រកបដោយសោមនស្សវេទនា តែប្រាសចាកប្រាជ្ញា មិនប្រកបដោយសង្ខារ ។

៤-សោមនស្សសហគត ញាណវិប្បយុត្ត សសង្ខារិក វិបាកចិត្តប្រកបដោយសោមនស្សវេទនា តែប្រាសចាកប្រាជ្ញា ប្រកបដោយសង្ខារ ។

៥-ឧបេក្ខាសហគត ញាណសម្បយុត្ត អសង្ខារិក វិបាកចិត្តប្រកបដោយឧបេក្ខាវេទនា និងព្រមដោយប្រាជ្ញា មិនប្រកបដោយសង្ខារ ។

៦-ឧបេក្ខាសហគត ញាណសម្បយុត្ត សសង្ខារិក វិបាកចិត្តប្រកបដោយឧបេក្ខាវេទនា និងព្រមដោយ ប្រាជ្ញា ប្រកបដោយសង្ខារ ។

៧-ឧបេក្ខាសហគត ញាណវិប្បយុត្ត អសង្ខារិក វិបាកចិត្តប្រកបដោយឧបេក្ខាវេទនា តែប្រាសចាកប្រាជ្ញា និងមិនប្រកបដោយសង្ខារ ។

៨-ឧបេក្ខាសហគត ញាណវិប្បយុត្ត សសង្ខារិក វិបាកចិត្តប្រកបដោយឧបេក្ខាវេទនា តែប្រាសចាកប្រាជ្ញា ប្រកបដោយសង្ខារ ។

វិបាកចិត្តទាំង៨នេះ ជាតួបដិសន្ធិ ជាពូជកំណើតលោកទុកដូចជាពូជស្រូវ ឬ ពូជដំណាំផ្សេងៗ មានពោតជាដើម ក្នុងការបង្កើតនូវដំណាំថ្មី។ មនុស្សក្នុងលោកដែលមានរូបពេញលក្ខណៈសម្បត្តិជាស្ត្រី ឬ បុរសមានប្រាជ្ញាយល់ដឹងច្រើន ហើយមានភោគសម្បត្តិសម្រាប់ប្រើប្រាស់ច្រើន ឬ ប្រកបអាជីវកម្មរស់នៅសុខស្រួល សុទ្ធតែអាស្រ័យនឹងវិបាកចិត្តនេះទាំងអស់។ វិបាកចិត្តនេះមានកិច្ច៥គឺ **ចុតិ, បដិសន្ធិ, ភវង្គ, សន្តីរណៈ** និងតទាលម្ពណៈ ។

~**ចុតិ** ឃ្លាតចាកនៅពេលដែលមនុស្សចូលកាន់មរណៈ(សេចក្តីស្លាប់) វិបាកចិត្តនេះឯងដែលរបូតចាក រូបកាយ។

-**បដិសន្ធិ** ចាប់កំណើតថ្មី (តភ្ជាប់ភព) នៅពេលដែលមនុស្សស្លាប់ម្តង១ ហើយត្រូវកើតក្នុងភពមនុស្ស និងទេវតា តួយ៉ាងដូចជាវិបាកចិត្តទី១ និងទី២ ដែលជាតួបដិសន្ធិរបស់មនុស្ស ដែលមានបុណ្យច្រើន កាលបើមនុស្សកើតឡើងហើយ មនុស្សនោះក៏រមែងពេញលេញដោយសម្បត្តិ៣គឺ **រូបសម្បត្តិ១. បញ្ញាសម្បត្តិ១. ទ្រព្យសម្បត្តិ១** ដោយពិត ។

-រូបសម្បត្តិ : មានអាយុវែង ពណ៌សម្បុរកាយល្អ កម្លាំងកាយពេញលេញ និងមិនមានជម្ងឺដម្កាត់ច្រើន បរិបូណ៌ដោយសុខភាព ។

-បញ្ញាសម្បត្តិ : មានប្រាជ្ញាច្រើនពីកំណើត រៀនឆាប់ចេះ ឆាប់យល់ រហូតក្លាយខ្លួនទៅជាអ្នកប្រាជ្ញ ឬ បណ្ឌិតក្នុងលោក ។

-ទ្រព្យសម្បត្តិ : កើតក្នុងត្រកូលអ្នកមានទ្រព្យសម្បត្តិសម្រាប់ប្រើប្រាស់បម្រុងជីវិត ជាត្រកូលស្តុកស្តម្ភពីកំណើត ។

-**ភវង្គ** : ខណៈចិត្តដែលកើតតពីបដិសន្ធិខណៈ នៅពេលដែលមនុស្សចាប់បដិសន្ធិក្នុងផ្ទៃមាតាម្តង១ វិញ្ញាណដែលចូលទៅចាប់បដិសន្ធិនោះ ក៏រលត់ភ្លឹបទៅតែម្តង បន្ទាប់មកក៏កើតវិញ្ញាណថ្មី តែវិញ្ញាណក្នុងទីនោះ មិនបានទទួលយកអារម្មណ៍អ្វីណាមួយឡើយ ។ វិញ្ញាណនេះក៏តាំងនៅជាប្រក្រតី មានជីវិតរស់នៅធម្មតាស្មើ១ ជាខណៈចិត្តដ៏បរិសុទ្ធស្អាត ដោយគ្មានគ្រឿងសៅហ្មង (កិលេស ឬ ឧបក្កិលេស) ចូលទៅប្រឡាក់ឡើយ ។

ខណៈចិត្តដ៏ស្អាតតាំងនៅស្មើៗ ដែលកើតតពីបដិសន្ធិនោះឯងហៅថា "**ភវង្គៈ**" រូបរាងកាយនៃមនុស្សម្នាក់ៗ បើគ្មាន **ភវង្គៈ** នោះកើតទេ ក៏មិនអាចកើតឡើងបានឡើយ ។

**-សន្តីរណៈ** ជាខណៈចិត្តសម្រាប់ពិចារណាក្នុងសម័យដែលអារម្មណ៍មានរូបារម្មណ៍ជាដើមមកប៉ះខ្ទប់នឹងទ្វារ មានចក្ខុទ្វារជាដើម តួយ៉ាងដូចជាបុគ្គលបានយល់ស្គាល់ច្បាស់ថា ជាមាតា ឬ បិតា អំ ក្អួយ ជាដើម សុទ្ធតែឆ្លងកាត់ការពិចារណានេះទាំងអស់ ។

**-តទាលម្ពណៈ** ខណៈចិត្តដែលផ្ចិតយកនូវអារម្មណ៍ ហើយចាំបាននូវពេលដែលខ្លួនបានធ្វើសកម្មភាពអ្វីមួយ តួយ៉ាងដូចជាចាំមេរៀន ចាំអំពើល្អៗគ្រប់បែបយ៉ាងដែលខ្លួនបានធ្វើដល់បុគ្គលដទៃជាដើម ។

**-រូបាវចរវិបាក៥**[១] **គឺៈ បឋមជ្ឈានវិបាក១, ទុតិយជ្ឈានវិបាក១, តតិយជ្ឈានវិបាក១, ចតុត្ថជ្ឈានវិបាក១, បញ្ចមជ្ឈានវិបាក១ រូបាវចរវិបាក** ទាំង៥នេះសុទ្ធតែជាតួបដិសន្ធិក្នុងរូបព្រហ្មទាំង១៦ មានព្រហ្មបារិសជ្ជាជាដើម ។

---

[១] : អភិធម្មត្ថសង្គហៈ ។

-អរូបាវចរវិបាក៤[២] គឺ : អាកាសានញ្ចាយតនៈ១, វិញ្ញាណញ្ចាយតនៈ១, អកិញ្ចញ្ញាយតនៈ១, នេវសញ្ញានាសញ្ញាយតនៈ១ ។

**អរូបាវចរវិបាក** ៤នេះសុទ្ធតែបដិសន្ធិក្នុងព្រហ្មគ្មានរូបទាំងអស់ ។

**ហេតុដែលនាំឱ្យមនុស្សកើតទៀត :**

មនុស្សម្នាក់ៗដែលស្លាប់ហើយកើតទៀតដោយហេតុអ្វីហ្ន៎ ?

ទស្សនៈក្នុងទ្រឹស្តីរបស់ព្រះពុទ្ធសាសនា បានបញ្ជាក់ថា :

សត្វលោកដែល អន្ទោលទៅ អន្ទោលមកក្នុងវាលវដ្តសង្សារ ព្រោះអាស្រ័យកម្មល្អ និងអាក្រក់ ដូចពុទ្ធដីកាពោលថា ក្នុងសម័យណាដែលពពួកសត្វធ្វើអំពើអាក្រក់ មានសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម ភូតភរកុហក ផឹកទឹកស្រវឹងជាដើម បន្ទាប់ពីសេចក្តីស្លាប់ សត្វនោះក៏ទៅកើតក្នុងកំណើតនរក ប្រេត អសុរកាយ និងតិរច្ឆាន លុះដល់កម្មនោះស្រាលស្តើង បានមកកើតជាមនុស្ស ។ មនុស្សនោះមានជម្ងឺច្រើន អាយុខ្លី បាត់បង់ទ្រព្យរកស៊ីខាត ខ្ញើយពីកំណើត ឬសម្បូរដោយសត្រូវ ត្រូវបានគេពោលបង្កាច់, ឆ្លូតវង្វេង, ល្ងង់ខ្លៅ[៣] ។

---

[២] : អភិធម្មត្ថសង្គហៈ ។
[៣] : គម្ពីរមង្គលត្ថទីបនី ។

នៅក្នុងសម័យណា ដែលពពួកសត្វកសាងខ្លួនបានល្អ មានឱ្យទាន រក្សាសីល ចម្រើនមេត្តាភាវនាឱ្យបានច្រើន លុះបន្ទាប់អំពីមរណៈ សត្វនោះរមែងទៅកើតក្នុងសុគតិសួគ៌[១] ។

ក្នុងអភិធម្មត្ថសង្គហៈ បានបញ្ជាក់ថា ៖

-**អកុសលចេតនា**[២] ទាំង១២ មានលោភមូល ៨ជាដើម បានញ៉ាំងមនុស្សសត្វឱ្យកើតប្រាកដក្នុងអបាយភូមិ មាននរកជាដើម ។

-**មហាកុសល** ទី៧ និងទី៨ បានញ៉ាំងមនុស្សឱ្យកើតជាមនុស្សវិញ តែមានបុណ្យតិច ។

-**មហាកុសលចេតនា** ៨ បានញ៉ាំងមនុស្សសត្វឱ្យកើតក្នុងកំណើតមនុស្ស[៣] និងទេវតា ។

-**រូបាវចរកុសលចេតនា** ៥បានញ៉ាំងមនុស្សសត្វឱ្យកើតក្នុងកំណើតព្រហ្មមានរូប ។

-**អរូបាវចរកុសលចេតនា** ៤ បានញ៉ាំងមនុស្សសត្វឱ្យកើតក្នុងកំណើត ព្រហ្មគ្មានរូប ។

---

១ : មនុស្ស និងទេវតា ។
២ : ជាតួអកុសលកម្ម ។
៣ : មនុស្សមានបុណ្យច្រើន ។

ដូច្នេះ មនុស្សដែលស្លាប់ហើយកើតជាថ្មីបន្តទៅទៀត គ្មានអ្វីក្រៅពីកុសលាកុសលកម្មឡើយ ។

កាលបើកុសលាកុសលកម្មនៅតែមានវិញ្ញាណដែលជាតួបដិសន្ធិក្នុងភព ក៏នៅតែមានបន្តឥតឈប់ឈរ ដូចជាខ្សែទឹកដែលហូរ ។

នៅក្នុងគម្ពីរទីឃនិកាយលេខ១៤ ព្រះពុទ្ធអង្គក៏ទ្រង់បានប្រកាសនូវវិជ្ជា៣ បញ្ជាក់សេចក្តីឱ្យឃើញប្រាកដថា ទាំងតថាគតក្តី ទាំងសត្វលោកដទៃក្តី ក្នុងសង្សារវដ្ត តាំងអំពីបឋមជាតិ មករហូតដល់សព្វថ្ងៃ ដែលអន្ទោលទៅអន្ទោលមក បានសោយនូវសេចក្តីទុក្ខខ្លះ សេចក្តីសុខខ្លះ ក៏សុទ្ធតែមកពីកុសលាកុសលកម្ម(១) ជាអ្នកតាក់តែងដូច។គ្នាទាំងអស់ ។

វិជ្ជាទាំងពាក់ **បុព្វេនិវាសានុស្សតិវិជ្ជា១, ចុតូបបាតវិជ្ជា១, អាសវក្ខយវិជ្ជា១** គឺព្រះអង្គទ្រង់បានសម្រេច តាំងពីថ្ងៃពុធ ១៥កើត ខែពិសាខ ឆ្នាំរការ មុនពុទ្ធសករាជ៤៥ឆ្នាំមកម្លេះ ។

-**បុព្វេនិវាសានុស្សតិវិជ្ជា** ចំណេះដឹងរលឹកឃើញជាតិកំណើតព្រះអង្គក្នុងកាលពីអតីត (ជាតិមុន) ដែលព្រះអង្គធ្លាប់កើតជាអ្វី។ ជាមនុស្ស ឬទេវតាជាដើម ។

-**ចុតូបបាតវិជ្ជា** ចំណេះដឹងមើលឃើញកិរិយាស្លាប់ និងយកកំណើតថ្មីក្នុងភពរបស់សត្វដទៃ ។

**-អាសវក្ខយវិជ្ជា** ចំណេះដឹងស្គាល់ច្បាស់ដឹងច្បាស់នូវធម៌ជាទី អស់ទៅនៃអាសវក្កិលេស មានកាមាសវៈជាដើម ។ មានរឿងជាភស្តុតាងជាច្រើន ដែលមានក្នុងគម្ពីរព្រះត្រៃបិដក ឬ គម្ពីរនានា ។ តែក្នុងទីនេះ ខ្ញុំសូមលើកយក រឿងខ្លះ១មកពោលទុក ដើម្បីភស្តុតាងដូចតទៅ:

**រឿងនាយចុន្ទសូករិកៈ**

នាយចុន្ទសូករិកៈ រស់នៅក្នុងនគរសាវត្ថី មានមុខរបររកស៊ីចិញ្ចឹមជីវិត ដោយការសម្លាប់ជ្រូកលក់ ។ គាត់បានសម្លាប់ជ្រូកយកសាច់លក់អស់ជាង ៥០ឆ្នាំ សាច់ជ្រូកដែលគាត់លក់នោះ គាត់បានយកទៅវាយដំ បញ្ចូលទឹកដើម្បីឱ្យសាច់ ជ្រូកឡើងទម្ងន់ នៅទីបំផុតនៃជីវិតគាត់មានជម្ងឺដ៏ធ្ងន់ រាងកាយរបស់គាត់ត្រូវ ក្តៅក្រហល់ក្រហាយ ស្បៀកសម្លៀកបំពាក់ពុំបាន គាត់ក៏ស្រាតមានកាយទទេ វារ ទៅវារមក ស្រែករោទិ៍ដូចជ្រូកអស់រយៈ៧ថ្ងៃ ក៏ចូលមរណៈកាល ។ បន្ទាប់ពី ស្លាប់ទៅ នាយចុន្ទសូករិកក៏បានទៅកើតក្នុងមហានរក ឈ្មោះអវិចី សោយទុក្ខ វេទនា ត្រូវភ្លើងនរកឆេះសព្វកាយ ។

**បញ្ជាក់** : នាយចុន្ទសូករិកៈ ដែលបានទៅកើតក្នុងកំណើតនរក ក៏ព្រោះតែ អកុសលកម្ម គឺសម្លាប់ជ្រូកនេះឯង ។

## រឿងក្រុមញាតិស្តេចពិម្ពិសារ

ជាង៩០ កប្បកន្លងទៅពីភទ្ទកប្បនេះ មានព្រះរាជាអង្គ១ ព្រះនាម ព្រះមហិន្ទ ដែលត្រូវជាបិតារបស់ ព្រះពុទ្ធព្រះនាមផុស្សៈ។

ព្រះរាជាអង្គនេះ មានព្រះរាជបុត្រ៣អង្គដទៃទៀត ដែលសុទ្ធតែជាមេទ័ព។ មេទ័ពទាំងបីរូបនោះ កូនបងទី១ មានទាហាន ៥០០នាក់ ជាបរិវារ កូនបងទី២ មានទាហាន ៣០០នាក់ កូនទី៣ មានទាហាន ២០០នាក់ ជាបរិវារ ក្រោយមកព្រះរាជបុត្រទាំង៣ ក៏បានព្រះបិតារាជានុញ្ញាតធ្វើបុណ្យឱ្យទានជាមួយព្រះពុទ្ធជាបងចំនួន៣ខែ ក៏បានចាត់ចែងឱ្យនាយស្មៀន និងនាយឃ្លាំងចាត់ចែងទាន។ ក្នុងពេលនោះមានកម្មករមួយចំនួន រួមទាំងកូន ប្រពន្ធ ទាំងអស់ ៨៤.០០០រូប បានទទួលភារកិច្ចជាអ្នកចំអិនម្ហូបអាហារប្រគេនព្រះសង្ឃច្រើនម៉ឺនអង្គ។ កម្មករទាំងនោះ បានចំអិនម្ហូបអាហាររួចហើយ ក៏នាំគ្នាបរិភោគមួយចំអែតម្នាក់ៗ សល់ប៉ុន្មានក៏ប្រគេនលោក។ ដោយបាបកម្មដែលខ្លួនធ្វើ លុះស្លាប់ទៅបានទៅកើតក្នុងអបាយ សោយទុក្ខវេទនាអស់ជាង ៩០កប្ប។ លុះដល់សម័យព្រះពុទ្ធព្រះនាម **សមណគោតម** កើតឡើងក្នុងលោក ទើបរួចចាកទុក្ខទោសដោយអំណាចស្តេចពិម្ពិសាលដែលត្រូវជាញាតិពីជាតិមុនធ្វើបុណ្យបញ្ជូនទៅឱ្យ។

**បញ្ជាក់** : ពួកជនចំនួន៨៤.០០០រូប ដែលកើតជាប្រេត សោយទុក្ខវេទនាអស់ជាង៩០កប្បក្នុងសំសារវដ្ត ក៏ព្រោះតែមកពីយកម្ហូបអាហារដែលជាទ្រព្យ

របស់គេមកបរិភោគមុនព្រះសង្ឃ ។

## រឿងបុរស២នាក់ជាបងប្អូនបង្កើត

ក្នុងត្រកូល១ មានបុរស២នាក់ជាបងប្អូនបង្កើត បុរសជាបងក៏មានប្រពន្ធ១។ បុរសនោះតែងយកចិត្តស្រឡាញ់ជាប់ចិត្តក្នុងរូបស្ត្រីជាប្រពន្ធនោះណាស់ ។ ក្រោយមកស្ត្រីជាភរិយា ក៏ទៅស្រឡាញ់បុរសជាប្អូនថ្លៃនោះ ទៀត។ ដោយសេចក្តីស្នេហាដែលគ្មានព្រំដែន បុរសជាប្អូនក៏សម្រេចចិត្តសម្លាប់បងប្រុសរបស់ខ្លួនដែលកំពុងដេកត្រង់មាត់ទ្វារផ្ទះ មានភ្នែកសម្លឹងភរិយារបស់ខ្លួនដោយក្តីស្នេហា។ បុរសជាបង នៅពេលដែលស្លាប់ទៅ បានទៅកើតជាពស់ផ្ទះ (ពស់តុកកែ) ភ្លាមមួយរំពេច។ ប្តី-ប្រពន្ធថ្មី ក៏រស់នៅជាមួយគ្នាដោយសេចក្តីសុខសាន្ត ក្រោយមក ពស់នោះធំឡើង នៅពេលដែលបុរសជាប្តីមិននៅផ្ទះ ពស់នោះក៏ចុះមកដើម្បីប្រឡែងលេងនឹងស្ត្រីជាភរិយាចាស់នោះ ដោយសម្គាល់ថាជាប្រពន្ធខ្លួន។ នាងនោះក៏ប្រាប់ដល់បុរសជាប្តីរបស់ខ្លួន បុរសជាប្តីនោះក៏សម្លាប់ពស់នោះទៅ។ នៅពេលដែលពស់នោះស្លាប់ វិញ្ញាណរបស់ពស់ក៏បានទៅកើតជាសត្វគោនៅនឹងផ្ទះនោះដដែល ។ នៅពេលដែលគោនោះធំ ដោយសេចក្តីអាល័យស្នេហាក្នុងស្ត្រីជាភរិយា គោនោះចេះតែលិទ្ធដៃ-ជើង រត់តាមនាង បុរសដទៃគេសើចចំអកឱ្យនាង និងគោឈ្មោលនោះ។ នាងជាអតីតភរិយានឹកខ្មាសគេក៏ប្រាប់ប្តីឱ្យប្តីសម្លាប់គោនោះចោល គោក៏ស្លាប់ទៅបានទៅកើតជាសត្វឆ្កែរស់នៅ